could be introduced to stimulate this discussion. Reflection on biblical values could follow to allow comparisons and contrasts. A similar process could be used with new Christians facing difficult decisions in living out the values of the Kingdom of God in the Cambodian cultural context.

Because of my limited knowledge of Cambodian culture and religion, I believe that this process of reflection and clarification of values must be done by Cambodian Christians, guided by scripture and the Holy Spirit. However, in order to outline how these stories may be used in community development practice, I will make the following preliminary suggestions.

O'Leary and Nee[19] have identified six core values of development practice: empowerment, participation, justice, sustainability, equity, and role. These values may be compared with traditional Cambodian values such as respect for authority, status, obedience, order, conformity, merit, charity, harmony, and consensus. The five folktales sketched above contain elements of these traditional values, as well as some core development values.

The story of the caterpillar and crow could be used to stimulate small group discussion on roles and relationships in community development, since mutual respect and trust lie at the core of successful development. The story of the deer, crow, and tortoise could also be used to probe personal relationships, but expanded to involve community participation (helping others and sharing resources) and equity (treating others as equals). Similar values from the teachings of Jesus could be introduced to allow comparisons and contrasts.

The story of the tiger and the hermit could aid community discussions where people are struggling against an unjust decision from biased or corrupt judges. One example might be a dispute over land ownership, where a more powerful and wealthy person has obtained legal title to land through unjust methods. Persistence in

---

[19]O'Leary, Moira, and Meas Nee, *Learning for Transformation*. Krom Akphiwat Phum, Phnom Penh, October 2001: 45, 63.

seeking justice is evident in this story, a theme that parallels Jesus' parable of the persistent widow.[20]

The story of the poor man and the axehead also involves seeking justice in the presence of unjust oppression, but could also lead into a discussion of the courage shown by the poor man in confronting the rich man and persisting in his attempts to obtain justice—an example of empowerment. An interesting discussion might also be stimulated by considering how the poor man made effective use of the local but limited resources available to him—one earthenware cooking pot!

The story of Mea Jurng again deals with seeking justice when faced with an unjust decision made by a person with power. The role of the four gatekeepers in advocating for justice could lead to fruitful community discussions. The story could also be used to explore first the innovation and empowerment of the intelligent wife, and then more general gender issues. The limited local resources of the poor family are effectively mobilized to achieve results. The wife actively builds the capacity of her new husband, and he is immediately able to apply what he has learned with good effect. This story further could illustrate the action learning cycle employed in community development (action–reflection–learning–planning–action).

It is my hope that this article will stimulate and encourage Cambodian Christians to seek values within their own rich culture and to creatively apply these values to sharing the Good News.

[20]Luke 18:1–8.

## References

CARRISON MD, 1987. *Cambodian Folk Stories: from the Gatiloke*. Charles E Tuttle.

DAVIDSON JHCS and CORDELL H, 1993. "The short stories of Cambodian popular tradition" in *The Short Story in South East Asia*, London, pp 37–61. Found in *Cambodian Linguistics, Literature and History: Collected Articles* by J Jacobs with D Smyth (ed). SOAS, University of London, pp. 243–54.

DIK-KEAM, 1962, *Cambodian Short Stories* (bilingual text, Khmer and English). [Publisher not known. Source—School of Oriental and African Studies Library, University of London.]

FLANNERY A (ed.), 1985. *Vatican Council II: The Conciliar and Post-Conciliar Documents.* Dominican Publications.

HIEBERT M, 1985. *Anthropological Insights for Missionaries*. Baker Book House.

HUFFMAN FC and PROUM IM, 1977. *Cambodian Literary Reader and Glossary.* Yale University Press.

INSTITUT BOUDDHIQUE, 1990. Collection of Cambodian Legends, Volumes 1–7. Ministry of Information reprint, Phnom Penh, Cambodia (Khmer language).

KING DW, 1978. "Christian ethics as moral ecology: towards the contextualization of ethics in a Southeast Asian culture," in *The South East Asia Journal of Theology*, 19:2:1978:26–37.

LAUSANNE COMMITTEE FOR WORLD EVANGELIZATION, 1975. *The Lausanne Covenant: an Exposition and Commentary by JRW Stott*. Lausanne Occasional Papers No. 3.

LAUSANNE COMMITTEE FOR WORLD EVANGELIZATION, 1980. *Thailand Report—Christian Witness to Buddhists*, Pattaya, Thailand, 16–27 June 1980. Lausanne Occasional Papers No. 15.

O'LEARY M and NEES M, 2001. *Learning for Transformation*. Krom Akphiwat Phum, Phnom Penh, Oct 2001.

RYKEN L, 1979. *Triumphs of the Imagination: Literature in Christian Perspective*. IVP.

TAYLOR M, 1990. *Good for the Poor: Christian Ethics and World Development*. Mowbray.

THIERRY S, 1985. *Le Cambodge des Contes*. Editions L'Harmattan, Paris.

សំណុំធីកឃ្មុំ ៤/១ (មករា ២០០៣)៖ ៣៩-៥០



# គុណតម្លៃរបស់សុភាទន្សាយ

*ឌូក្លាស ហ្សូរ*

## សេចក្ដីផ្ដើម

ទេវសាស្ត្រទាំងអស់តែងតែពឹងផ្អែកលើការសង្កេតឲ្យយល់ ការត្រិះរិះពិចារណា និងការឆ្លើយតបទៅនឹងភស្ដុតាងនៃស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា សូម្បីតែនៅកន្លែងដែលមិនទាន់មាននរណាស្គាល់ព្រះយេស៊ូ ជាព្រះអម្ចាស់នៅឡើយក៏ដោយ ។ វិធីដោះស្រាយនេះត្រូវបានគណៈនិកាយធំៗទាំងអស់នៃក្រុមជំនុំគ្រីស្ទបរិស័ទទទួលគាំទ្រ ។[1] វប្បធម៌ទាំងអស់មានគុណតម្លៃអាចយក

---

*អត្ថបទនេះដកស្រង់ចេញពីនិក្ខេបបទរបស់អ្នកនិពន្ធក្នុងឱកាសទទួលបរិញ្ញាប័ត្រ ខាងបេសកកម្មវិទ្យាពីសកលវិទ្យាល័យអូផិន ក្រោមចំណងជើងថា "សុភាទន្សាយ និងអាណាចក្រព្រះ" ដែលគាត់សរសេរឡើងក្នុងឆ្នាំ ១៩៩៤ នៅមហាវិទ្យាល័យអលណេស្បិន នៅឯប្រទេសអង់គ្លេស ។*

*[1]កិច្ចព្រមព្រៀងនៅក្នុងក្រុង ឡូសាន បានគាំទ្រចំពោះវិធីសាស្ត្រត្រួសត្រាយ ផ្លូវដែលប្រកបដោយការប្រើសេចក្ដីស្រមៃដើម្បីផ្សាយដំណឹងល្អឲ្យស៊ីនឹងទំនៀមទំលាប់ ។ នៅក្នុងការបន្ទាល់របស់គ្រីស្ទបរិស័ទចំពោះពុទ្ធសាសនិកជននោះ ក្រុមទាំងការប៉ុនប៉ងទាំងឡាយ គឺដើម្បីស្វែងរកការគួសបញ្ជាក់*

មកឲ្យគេអះអាងផង និងយកមកបបួលគេឲ្យទទួលស្គាល់ផង ។ គ្រីស្ត បរិស័ទដែលកំពុងស្វះស្វែងចង់រស់នៅតាមគុណតម្លៃដែលបំផ្លាស់បំប្រែជីវិត អាចឆ្លើយតបទៅនឹងប្រព័ន្ធគុណតម្លៃផ្សេងៗដោយពាក្យនៃការ យល់ដឹង និងពាក្យពេញចិត្តក៏បាន ដោយពាក្យរិះគន់ និងទិតៀនក៏បាន និងដោយពាក្យនៃក្តីសង្ឃឹមថាមានការផ្លាស់ប្រែក៏បាន ។[២] ទោះជាយ៉ាង ណាក៏ដោយគ្រីស្តបរិស័ទ ជាពិសេសចំពោះអ្នកទាំងឡាយដែលមកពី វប្បធម៌ផ្សេងពីកន្លែងដែលខ្លួនកំពុងបំរើការនោះ ត្រូវតែបញ្ជាក់ពី ជំហររបស់ខ្លួនជាមុន និងព្រមឲ្យអ្នកដទៃសម្រេចពីគុណតម្លៃរបស់ខ្លួនគេ ផ្ទាល់[៣] ។

ដំណើរការនៃការសម្របឲ្យស្របទៅនឹងស្ថានការណ៍ គឺចាំបាច់ ដែលត្រូវគិតគូរ ។ ការប្រចាប់ជំនឿសាសនាពីរចូលគ្នានោះទទួលលទ្ធ ផលបានមកពីវិធីដោះស្រាយចំពោះគុណតម្លៃ ដែលមានស្រាប់នៅ កន្លែងនោះ គេព្រមទទួលយកឬក៏មានប្រព័ន្ធគុណតម្លៃមកពីបរទេស ត្រូវគេយកមកដាក់ជំនួសរួចទៅហើយ ។[៤] ការធ្វើឲ្យស៊ីនឹងស្ថានការណ៍ ដ៏គួរឲ្យប្រុងប្រយត្ន័នេះ ត្រូវតែសង្កត់ធ្ងន់លើចំណុចសំខាន់របស់ព្រះគម្ពីរ តួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ និងការចូលរួមយ៉ាងសកម្មរបស់ សហគមន៍គ្រីស្តបរិស័ទក្នុងការវាយតម្លៃលើកិច្ចការនោះ ។

---

*ពន្យល់នៅក្នុង ស្រុកណាមួយដើម្បីឲ្យគេយល់ពិសេចក្តីពិតផ្នែកទេវសាស្ត្រនោះ គឺបាន ទទួលនូវការលើកទឹកចិត្តឲ្យធ្វើ* (LCWE *១៩៨០:៩,២៥*) ។ Ad Gentes *បានសុំឲ្យយើងបើកបង្ហាញដោយអំណរ និងដោយគោរពនូវគ្រាប់ពូជ ដែលបានលាក់ទុក នៅក្នុងចំណោមទំនៀមទំលាប់ទាំងឡាយ* (Flannery *១៩៧៥*) ។

[2] King 1978:27

[3] Taylor 1990:36-7.

[4] Hiebert 1985:183-9.

## អត្ថរសនៅក្នុងអក្សរសិល្ប៍

អក្សរសិល្ប៍ដែលប្រកបដោយឧបមេយ្យកថា ដែលគេពិពណ៌នាថា "ការចង្អុលបង្ហាញយ៉ាងច្បាស់ពីអត្ថរស (គុណតម្លៃ) របស់មនុស្ស ការប្រាថ្នាចង់បាន និងសេចក្ដីទុក្ខព្រួយទាំងពួងដែលកំពុងតែកើតមានឡើងនោះ" ។ អក្សរសិល្ប៍បែបនោះមិនគ្រាន់តែផ្ដល់ឱកាសឲ្យយើងមានការយល់ដឹងពីអត្ថរសទាំងឡាយដូចជា សេចក្ដីស្រឡាញ់ ឬយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែអនុញ្ញាតឲ្យយើងបានបញ្ជាក់ពីគុណតម្លៃផ្ទាល់របស់យើង និង ពិចារណាដោយគោរពរាប់អានដល់គតិលោកផ្សេងទៀត ដែលយើងមិនអាចយល់ព្រមទទួលបាននោះ ។[5] អក្សរសិល្ប៍រឿងព្រេងបង្ហាញជាពិសេសអំពីគ្រឹះនៃជំនឿទាំងឡាយស្ដីពីនិស្ស័យលក្ខណៈនៃរឿងរ៉ាវជាច្រើន។ [6]

## រឿងព្រេងខ្មែរ

រឿងព្រេងផ្នែកអក្សរសិល្ប៍ខ្មែរភាគច្រើនផុលផុសឡើងយ៉ាងខ្លាំងនៅក្នុងរយៈពេលមួយពាន់បីរយឆ្នាំ ដោយហេតុថាសិលាចារឹកខ្មែរដើមដំបូងគេនោះកើតមាននៅក្នុងសតវត្សរ៍ទី១៧ ។ អក្សរសិល្ប៍នេះមានសន្ទុះ និងទទួលឥទ្ធិពលពីប្រភពជនជាតចិន ហិណ្ឌូ ពុទ្ធសាសនិកជនថៃ និងបារាំង ។[7] តួអង្គខ្លះនៅក្នុង រឿងព្រេងខ្មែរ ដូចជាតួអង្គអ្នកតាគឺមានពីមុនគ្រិស្តសករាជមកម្ល៉េះ ។ រឿងព្រេងទាំងឡាយនេះបានហូរចូលមកក្នុងប្រទេសខ្មែរស្របគ្នាទាំងពីរ ទាំងការនិយាយផ្ទាល់មាត់ និងសំណេរឆ្លងកាត់ចូលមក ដែលមានការកែសម្រួលពីមួយ

[5] Ryken 1979:27, 76,102,145.
[6] Hiebert 1985:175.
[7] Huffman and Proum 1977:1
[8] Thierry 1985:34,63.

ជំនាន់ទៅមួយជំនាន់ ។[៨] អក្សរសិល្ប៍ទាំងនោះ គេបានបោះពុម្ពជាលើកដំបូងនៅចុងសតវត្សរ៍ទី១៩ ដោយដកស្រង់ចេញពីសាស្ត្រាស្លឹករិត ដែលមានតម្កល់ទុកនៅតាមបណ្ណាល័យនៅក្នុងវត្តអារាម ។[៩] មានប្រជុំរឿងព្រេងខ្មែរពីរសំខាន់ៗគឺ ប្រជុំរឿង ព្រេងផ្នែកពុទ្ធសាសនបណ្ឌិត និងផ្នែកគតិលោក ។ ការប្រមូលចងក្រងប្រជុំរឿងព្រេងរបស់ពុទ្ធសាសនបណ្ឌិតមានប្រាំពីរ ឬប្រាំបួនក្បាល រីឯផ្នែកគតិលោកវិញ គឺផ្អែកលើសេចក្តីបង្រៀនផ្នែកពុទ្ធសាសនាវិញ ។

រឿងភាគច្រើនស្តីពីជីវិតរស់នៅរបស់មនុស្សសាមញ្ញ និងការងាររបស់គេនៅតាមភូមិ តាមទីក្រុង និងនៅតាមដងព្រៃព្រឹក្សា ដែលផ្តល់នូវការយល់ដឹងស៊ីជម្រៅទៅក្នុងទំនៀមទំលាប់នៃសង្គមខ្មែរពីបូរាណកាល និង សង្គមបច្ចុប្បន្ន ព្រមទាំងសីលធម៌រស់នៅរបស់ខ្មែរ ។[១០] ខ្លឹមសារនៃផ្ទៃរឿងជាសាកលប្រាំយ៉ាង ត្រូវបានគេលាតត្រដាងឲ្យឃើញនៅក្នុងរឿងព្រេងទាំងនោះគឺ: ការបាត់បង់ គ្មានភាពស្និទ្ធស្នាល ការទាមទារចង់បានអំណាចវេទមន្ត ការរងខ្លោចផ្សា ឬការតស៊ូស្វិតស្វាញ និងការដែលកាន់តែមានស្មុកស្មាញឡើង ឬមានឋានៈខ្ពង់ខ្ពស់ ។[១១] លក្ខណៈពិសេសជាច្រើននៃជំនឿពុទ្ធសាសនាផ្នែកមហាយាន គឺគេបានប្រទះឃើញនៅក្នុងរឿងព្រេងទាំងនេះ ។[១២] អំពើល្ងង់ខ្លៅ និងអំពើលោភលន់របស់ពួកស្តេចមន្ត្រី និងព្រះរបស់ពួកហិណ្ឌូពីបុរាណនោះគឺផ្ទុយគ្នាស្រឡះពីទឹកចិត្តសប្បុរស និងសេចក្តីមេត្តាករុណារបស់ជនសាមញ្ញ ។ សមភាពរវាងស្ត្រីនិងបុរសនោះ បង្ហាញឲ្យឃើញមានភាពតានតឹង ដោយព្រោះតែឧត្តម

[9] Davidson and Cordell 1993:253.
[10] Huffman and Proum 1977:4-5
[11] Thierry 1985:218
[12] Carrison 1987:15-16

ភាពរបស់បុរសដែលយកគំរូតាមព្រហ្មញ្ញសាសនាពីបុរាណកាលនោះឯង ។ ការទទួលខុសត្រូវរបស់បុគ្គលម្នាក់គឺបញ្ជាក់ឲ្យឃើញច្បាស់ដោយការខ្វះនូវការអាណិតអាសូរដល់ជនរងគ្រោះឆោតល្ងង់ព្រោះ តែអំពើបោកបញ្ឆោត ។ ផលកម្មជាអ្នកសំរេចដាក់ទណ្ឌកម្ម និងផ្តល់រង្វាន់នោះគឺជាការដែលមិនអាចគេចផុត ប៉ុន្តែស៊ីពេលយូរបន្តិច ។ នៅក្នុងសាច់រឿងទាំងនោះអំពើកាប់សម្លាប់គឺជាការហាមប្រាមរបស់លទ្ធិពុទ្ធនិយមដែលពួកសត្វស្លូតៗ និងមានប្រាជ្ញាត្រូវគេប្រហារយ៉ាងឃោរឃៅ ហើយរឿងនោះក៏ចែងពីព្រានព្រៃដែលមិនរវៀសរវៃដែរ ។

នៅក្នុងចំណោមរឿងដែលពេញនិយមបំផុតនោះគឺរឿងសុភាទន្សាយ ។ មានរឿងមួយក្រុមនិយាយពីសត្វដែលវៃឆ្លាតខំគេចវេះពីសេចក្តីស្លាប់តែប៉ុណ្ណោះ ឯរឿងក្រុមទីពីរនេះដែលចែងពីសុភាទន្សាយវិញគឺស្តែងចេញពីទេពកោសល្យនៃការកាត់ក្តី ។[១៣] យុត្តិធម៌ សម្រេចនៅក្នុងជម្លោះផ្នែកផ្លូវច្បាប់រវាងមនុស្ស និងសត្វ ដែលតាមធម្មតាបានមកពីល្បិចចាក់បណ្តោយ ឬការបញ្ឆោតប្រកបដោយភាពវៃឆ្លាតនៃការប្រើពាក្យសំដី ។ ទោះជាយ៉ាងណាក៏ដោយទន្សាយមិនបានឈរលើជំហរយុត្តិធម៌រហូតនោះឡើយ ។

## រឿងព្រេងខ្មែរប្រាំយ៉ាង

បង្ហាញពីទិដ្ឋភាពនៃការទទួលខុសត្រូវទៅវិញទៅមក និងការទុកចិត្តគ្នាចំពោះទំនាក់ទំនងយ៉ាងល្អនោះមានបង្ហាញនៅក្នុងសាច់រឿងដូចតទៅនេះ ។ សត្វដង្កូវ ត្រូវសត្វក្អែកបំរុងនឹងចឹកស៊ីនោះ បង្កប់នូវ

---

[13] There are similar stories in Laos and Vietnam and parallels with the mouse-deer (*Palanduk*) stories in of the Malay (Davidson and Cordell 1993:245).

សំណួរបួនដែលពិបាកឆ្លើយនោះគឺៈ តើអ្វីដែលជារបស់ផ្អែមជាងគេបំផុត ជូរបំផុត ស្អុយបំផុត និងក្រអូបបំផុតនៅក្នុងលោក? សត្វក្អែកឆ្លើយមកវិញតាមន័យត្រង់ថា៖ ផ្អែមជាងគេគឺទឹកឃ្មុំ ជូរជាងគេគឺក្រូចឆ្មារ ស្អុយជាងគេគឺលាមក ហើយក្រអូបជាគេគឺផ្កាម្លិះ ។ ជីវិតរបស់សត្វជង្គ្រងនោះបានរួចខ្លួន ដោយព្រោះក្អែកឆ្លើយមិនត្រូវ ជង្គ្រងក៏ផ្តល់ចម្លើយតាមបែបត្រឹមត្រូវថា សេចក្តីស្រឡាញ់ និងភក្តីភាពជាអ្វីដែលផ្អែមបំផុត ពាក្យសំដីព្យាបាទជាអ្វីដែលជូរបំផុត កេរ្តិ៍ឈ្មោះអាក្រក់ជាអ្វីដែលស្អុយបំផុត ហើយកេរ្តិ៍ឈ្មោះល្អស្មោះត្រង់និងថ្លៃថ្នូរនោះហើយជា អ្វីដែលក្រអូបបំផុតនោះ ។[14] មានរឿងមួយទៀតដែលទាក់ទងទៅនឹង សត្វក្តាន់ សត្វក្អែក និងអណ្តើក ដែលបង្ហាញពីគុណសម្បត្តិនៃកល្យាណមិត្ត ដែលស្ម័គ្រចិត្តព្រមជួយគ្នាទៅវិញទៅមក និងចេះចែករំលែកធនធានជាមួយគ្នា និយាយស្មោះត្រង់ ប្រព្រឹត្តនឹងគ្នាទៅវិញទៅមក ដោយចាត់ទុកថាមានតម្លៃស្មើគ្នា ។[15]

មូលហេតុដែលបណ្តាលឲ្យមានការសម្រេចចិត្តមិនយុត្តិធម៌បែបនេះគឺមកពីសេចក្តីប៉ងប្រាថ្នាផ្ទាល់ខ្លួន ចិត្តលោភលន់ ចិត្តភ័យខ្លាច ចិត្តសំអប់ និងចិត្តមិនអើពើដែលយើងប្រទះឃើញនៅក្នុងរឿងសត្វខ្លាដែលត្រូវពស់វែកចឹកស្លាប់ស្តូកស្តឹង តែបានតាឥសីមកប្រោសឲ្យរស់ឡើងវិញ ។ [16] ពេលនោះសត្វខ្លាកំណាចនោះបានគំរាមចង់ស៊ីតាឥសីនោះវិញ ដោយចោទថាគេកំពុងដេកលក់ស្រួល ស្រាប់តែតាឥសីទៅដាស់ឲ្យភ្ញាក់ ។ ទំនាស់បានកើតឡើងរួចភាគីទាំងសងខាងទៅប្តឹងសត្វដទៃទៀតឲ្យជួយកាត់ក្តី ។ សត្វដទៃបានកាត់ក្តីហាក់ដូចជាកាន់ជើងសត្វខ្លា

---

[14] *វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត ប្រជុំរឿងព្រេងភាគ ១:២៣*

[15] Dik-Kem 1962:36-38 *(អត្ថបទសិក្សាភាសាខ្មែរអង់គ្លេស)*

[16] *វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត ប្រជុំរឿងព្រេងភាគ ៣:១*

ព្រោះសត្វ ទាំងនោះដូចជាត្នោតជាដើមរស់នៅពឹងអាស្រ័យលើចំណីដែល
សល់ពីខ្លា ។ គោមិនហ៊ានកាត់ក្ដីឲ្យត្រូវទេ ព្រោះខ្លាចខ្លា ចំណែកឯស្វា
និងអារុក្ខអារក្សថែរក្សាព្រៃកំពុងរកឱកាសសងសឹកនឹងមនុស្ស ទើប
កាត់ក្ដីកាន់ជើងខ្លា ។ ចៅក្រមកាត់ក្ដីក្រោយគេនេះ គឺជាសុភាទន្សាយ
ដែលជាអ្នកមើលឃើញ ពីភាពលំអៀងរបស់ពួកចៅក្រមទាំង៥នាក់ខាង
ដើម ហើយសុភាទន្សាយក៏បានស្នើថា ដើម្បីឲ្យមានភាពយុត្តិធម៌នោះ
ចូរឲ្យធ្វើសកម្មភាពនោះសាឡើងវិញ គឺឲ្យខ្លាទៅដេកនៅមាត់រូងពស់
វែកដូចមុន ។ ពេលពស់ចឹកខ្លាងាប់ម្ដងទៀត គាត់សឹមិនបានប្រោសខ្លាឲ្យ
រស់ឡើងវិញដូចមុនទេ!

មាណពកំសត់ក្រីក្រម្នាក់បានខ្ចីពូថៅគេទៅកាប់ឈើ ដោយ
ចៃដន្យផ្លែពូថៅនោះក៏របូតធ្លាក់បាត់ទៅ ។ [១៧] អ្នកមានដែលជាម្ចាស់ផ្លែ
ពូថៅនោះបានអះអាងថា នេះជាផ្លែពូថៅកេរ្តិ៍ដ៏មានតម្លៃនៅក្នុងគ្រួសារ
របស់គេ ទោះបើត្រូវសងផ្លែពូថៅប្រាំពីរក៏ដោយក៏គេមិនព្រមទទួលដែរ។
គួរឲ្យអាសូរដល់បុរសកំសត់ដោយមិនអាចរកផ្លែពូថៅនោះសងគេបាន ក៏
បានយកកូនប្រុសរបស់ខ្លួនឲ្យទៅស៊ីឈ្នួលបុរស អ្នកមានម្នាក់នោះ ។ មិន
យូរប៉ុន្មានបុរសកំសត់បានរកផ្លែពូថៅនោះឃើញវិញ គាត់មានសេចក្ដី
អំណរខ្លាំងណាស់ គាត់ក៏បានទៅលោះកូនរបស់គាត់ពីអ្នកមាននោះវិញ ។
លុះចំណោរតមក កូនស្រីរបស់បុរសដែលជាសេដ្ឋី នោះចង់បានសម្លធ្លាញ់
ដែលប្រពន្ធរបស់បុរសអ្នកក្រនោះធ្វើ ។ ដើម្បីឲ្យបានតម្រូវចិត្តកូនស្រី
លោកសេដ្ឋីក៏ទៅខ្ចីឆ្នាំងដីរបស់បុរសអ្នកក្រ ដើម្បីមករៀបចំម្ហូបចំណីឲ្យ
កូនស្រី តែទេសកាលអ្វីឆ្នាំងដីក៏ត្រូវបែកខ្ទេចអស់ទៅ ។ បុរសក្រីក្រនោះ
ពិបាកចិត្តយ៉ាងខ្លាំង ហើយបានអះអាងថា ឆ្នាំងដីនោះជាកេរ្តិ៍មត៌ករបស់

---

[17] *វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត ប្រជុំរឿងព្រេងភាគ ៧:៤៦*

គ្រួសារ ទោះបើត្រូវសងឆ្នាំងដីថ្មី១០ក៏មិនព្រមទទួលយកដែរ! បន្ទាប់ពីបានទទួលការកាត់ក្តីដែលមិនប្រកបដោយយុត្តិធម៌មក បុរសអ្នកក្រក៏ទូលអង្វរដល់ស្តេចដើម្បីជួយរកយុត្តិធម៌ឲ្យ ព្រោះស្តេចធ្លាប់កាត់ក្តីឲ្យកាលពីរឿងក្តីផ្លែពូថៅ ។ ដើម្បីផ្តល់នូវភាពយុត្តិធម៌ ព្រះរាជាក៏បញ្ជាឲ្យអ្នកមានលើកកូនស្រីរបស់ខ្លួនឲ្យធ្វើជាប្រពន្ធកូនប្រុសរបស់បុរសអ្នកក្រ!

រឿង មាយើង មានរឿងខ្លីៗបួនភាគដែលគេពេញនិយម ។[១៨] រឿងនេះបញ្ជាក់បន្ថែមលើសេចក្តីយុត្តិធម៌ រឿងនេះលើកតម្កើងគុណធម៌របស់ស្ត្រីម្នាក់ដែលមានប្រាជ្ញាគឺជាស្ត្រីគ្រប់លក្ខណ៍ ។ បុរសដែលច្រណែននឹងគេបានសុំប្តូរប្រពន្ធរបស់ខ្លួនជាមួយនឹងស្រីស្រស់ស្អាត តែឥតមានប្រាជ្ញាដែលជាប្រពន្ធរបស់បុរសក្រីក្រ ។ តាមរយៈនៃការឆ្លាតវៃរបស់នាង អ្នកជិតខាងរបស់នាងគោរពរាប់អាននាងជាទីបំផុត ហើយដោយសារតែនាងទើបប្តីថ្មីរបស់នាងបានការងារធ្វើនៅឯរាជវាំង ។ នៅពេលដែលស្តេចចេញបរបាញ់សត្វដោយជិះសេះចូលទៅក្នុងព្រៃជ្រៅនោះ មានតែមាយើងទេដែលអាចទៅទាន់ស្តេច និងថ្វាយការបំរើដល់ស្តេចដោយព្រោះតែគាត់បានប្រពន្ធដែលចេះជួយផ្តល់គំនិតឲ្យគាត់ទើបគាត់អាចរៀបចំធ្វើម្ហូបថ្វាយស្តេចសោយបាន ។ គាត់បានពុអារុក្ខអារក្សថែរក្សាព្រៃរៀបចំគម្រោងធ្វើឃាតដល់ស្តេច ហើយគាត់បានព្យាយាមជួយសង្គ្រោះស្តេចបានពីរលើក ។ នៅពេលយប់មួយនោះ គាត់បានសម្លាប់សត្វពស់មួយយ៉ាងធំ នៅក្នុងកន្លែងដែលស្តេចផ្ទំ ប៉ុន្តែគាត់បានធ្វើឲ្យមហេសីស្តេចភ្ញាក់ ដោយគាត់កំពុងតែព្យាយាមជូតស្នាមឈាមដែលប្រឡាក់នៅលើដើមទ្រូងរបស់ព្រះនាង ។ ពេលនោះស្តេចក្រេវក្រោធយ៉ាងខ្លាំង ហើយបានបញ្ជាឲ្យគេយកគាត់ទៅប្រហារជីវិតភ្លាម ប៉ុន្តែដោយសារអ្នកឆ្មាំវាំងបួននាក់បានជួយរំដោះមាយើងឲ្យរួចពីកណ្តាប់

18 *វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត ប្រជុំរឿងព្រេងភាគ ៤:៤*

ដៃពេជ្ឈឃាត ដោយពន្យារដំណើរមិនឲ្យពួកគេចេញពីវាំងជាមួយនឹងមាយើងឡើយ ។ ពួកអ្នកផ្ទាំវាំងនិយាយពីរឿងផ្សេង ដោយមានបំណងចង់បង្ហាញថា ស្តេចបានធ្វើការសម្រេចព្រះហឫទ័យកាត់ទោសដោយមិនបានពឹងផ្អែកលើច្បាប់ឡើយ ។ នៅពេលព្រឹកឡើង នៅក្នុងពេលធ្វើសវនាការ ស្តេចនឹកចាំការបំរើដ៏ល្អរបស់មាយើងពីមុនៗ ហើយបានប្រទះឃើញខ្មោចសត្វពស់នៅក្រោមគ្រែរបស់ខ្លួន ។ ស្តេចបានកោតសរសើរមាយើង និងប្រទានមុខតំណែងខ្ពង់ខ្ពស់ដល់គាត់ថែមទៀត!

## គុណតម្លៃរបស់សុភាសិតឧទាហរណ៍

ខ្ញុំជឿថារឿងព្រេងទាំងប្រាំនេះមានបង្កប់នូវគុណតម្លៃដែលគួរឲ្យយើងកត់សំគាល់ ។ ហេតុដូច្នេះហើយប្រជុំរឿងព្រេងខ្មែរអាចផ្តល់នូវឱកាសដ៏ល្អសំរាប់ការត្រិះរិះពិចារណា និងការបញ្ជាក់ឲ្យបានច្បាស់ពីគុណតម្លៃនៃទំនៀមទម្លាប់ជាច្រើន ។ ឧទាហរណ៍នៅក្នុងទម្លាប់នៃការអភិវឌ្ឍន៍ក្នុងសហគមន៍ គឺសហគមន៍ខ្មែរត្រូវតែលើកទឹកចិត្តឲ្យធ្វើការពិភាក្សាពីគុណតម្លៃត្រង់ៗតែម្តង ដែលទាក់ទងទៅនឹងកម្មវិធីអភិវឌ្ឍន៍ ។ យើងអាចជ្រើសយករឿងព្រេងទាំងឡាយនេះមកបំផុសគំនិតនៅពេលពិភាក្សា ។ បន្ទាប់ពីនោះមក គឺយើងលើកយកគុណតម្លៃរបស់ព្រះគម្ពីរយកមកពិភាក្សាតាមក្រោយ ដើម្បីឲ្យយើងអាចធ្វើការប្រៀបធៀប និងមើលពីភាពផ្ទុយគ្នារវាងគុណតម្លៃរបស់រឿងព្រេងទាំងនោះ ។ យើងអាចប្រើវិធីរបៀបនេះដែរ សំរាប់អ្នកជឿថ្មីដែលកំពុងជួបប្រទះនូវការលំបាកចំពោះការសម្រេចចិត្តរស់នៅក្រៅរង្វង់នៃគុណតម្លៃរបស់អាណាចក្រព្រះដើម្បីឲ្យស៊ីនឹងស្ថានភាពវប្បធម៌របស់ខ្មែរនោះ ។

ដោយសារតែចំណេះដឹងរបស់ខ្ញុំចំពោះវប្បធម៌ និងជំនឿសាសនារបស់ខ្មែរនៅមានដែនកំណត់ ខ្ញុំជឿថាដំណើរការសញ្ជឹងគិត

និងប្រកាសយ៉ាងច្បាស់ពីគុណតម្លៃនេះ ·គ្រីស្តបរិស័ទខ្មែរត្រូវតែធ្វើការបកស្រាយដោយយកព្រះគម្ពីរជាគោល និងពឹងអាងលើអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យព្រះអង្គដឹកនាំ ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីលើកយកគោលសំខាន់ៗនៃសាច់រឿងទាំងនេះមកប្រើនូវក្នុងការអនុវត្តន៍ក្នុងកម្មវិធីអភិវឌ្ឍន៍នោះ ខ្ញុំសូមស្នើចំណុចសំខាន់ៗដូចតទៅ ។

អូ លារី និង នី[19] បានបង្ហាញឲ្យឃើញពីចំណុចសំខាន់ ៦ចំណុចនៃគុណតម្លៃនៅក្នុងទម្លាប់នៃការអភិវឌ្ឍន៍ គឺៈ ការផ្តល់អំណាច ការចូលរួមយុត្តិធម៌ និរន្តភាព សមភាព និងតួនាទី ។ គុណតម្លៃទាំងនេះអាចប្រៀបធៀបជាមួយនឹងគុណតម្លៃនៃទំនៀមទម្លាប់របស់ខ្មែរ ដូចជាការគោរពដល់អាជ្ញាធរ ការគោរពឋានៈ ស្តាប់បង្គាប់ បញ្ជា ការយកតម្រាប់តាម សន្សំកុសល ចិត្តសប្បុរស ការចុះសម្រុងនឹងគ្នា និងមតិភាគច្រើន ។ រឿងព្រេងទាំងប្រាំយ៉ាងនេះ បង្ហាញពីគុណតម្លៃទាំងប៉ុន្មាន ខាងលើដែលជាគុណតម្លៃនៃទំនៀមទម្លាប់ ក៏ដូចជាគុណតម្លៃនៃការអភិវឌ្ឍន៍នោះដែរ ។

រឿងដង្កូវ និងក្អែក អាចយកទៅប្រើក្នុងការពិភាក្សាជាក្រុមតូចដើម្បីឆ្លុះបញ្ចាំងពីតួនាទី និងទំនាក់ទំនងក្នុងការអភិវឌ្ឍន៍សហគមន៍ ដោយហេតុថាការគោរពគ្នាទៅវិញទៅមក និងចំណងនៃការទុកចិត្តគ្នានោះអាចធ្វើឲ្យការអភិវឌ្ឍន៍ទទួលបានជោគជ័យ ។ រឿង ក្តាន់ ក្អែក និងអណ្តើកអាចយកទៅប្រើដើម្បីស្ទង់មើលពីទំនាក់ទំនងផ្ទាល់ខ្លួន តែយើងអាចពង្រីកទៅដល់ការចូលរួមរបស់សហគមន៍ (ដែលគេចេះចែករំលែកធនធានគ្នាទៅវិញទៅមក) និងសមភាព (ដោយការចេះឲ្យតម្លៃគ្នាទៅវិញទៅមក) ។ សេចក្តីបង្រៀនរបស់ព្រះយេស៊ូក៏មានគុណតម្លៃស្រដៀងគ្នានេះ

[19] O' Leary, Moira , and Meas Nee, Learning for Transformation. Krom Akphiwat Phum, Phnom Penh, October 2001: 45,63 .

ដែរ ដែលយើងអាចលើកមកធ្វើការប្រៀបធៀប និងមើលពីភាពផ្ទុយគ្នានោះ ។

រឿងខ្លា និងតាឥសី អាចយកមកបន្ថែមនៅក្នុងការពិភាក្សានៅក្នុងសហគមន៍ នៅពេលដែលប្រជាជនជួបប្រទះនូវការសម្រេចចិត្តណាមួយដែលមានភាពលំអៀង ដែលមិនយុត្តិធម៌ ឬដោយសារចៅក្រមពុករលួយ ។ ដោយលើកឧទាហរណ៍ពីរឿងទំនាស់ដីធ្លីណាមួយមកពិភាក្សា ដែលអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាចអាចទទួលយកដីធ្លីនោះនៅក្រោមរូបភាពស្របច្បាប់ណាមួយ ដែលបណ្ដាលមកពីការសម្រេចក្ដីដោយអំពើអយុត្តិធម៌នោះ ។ ការព្យាយាមមិនចុះញ៉មដើម្បីរកយុត្តិធម៌នៅក្នុងសាច់រឿងនោះបានបង្ហាញយ៉ាងច្បាស់ ដែលមានភាពស្រដៀងគ្នាទៅនឹងរឿងប្រៀបប្រដូចរបស់ព្រះយេស៊ូ ស្ដីពីការខំព្យាយាមរបស់ស្ត្រីមេម៉ាយ ។[២០]

រឿងរបស់បុរសអ្នកក្រនិងផ្លែពួចៅ ក៏បង្ហាញពីភាពតស៊ូព្យាយាមរកយុត្តិធម៌ក្រោមការសង្កត់សង្កិនដ៏អយុត្តិធម៌ពីសំណាក់អ្នកកាត់ក្ដីមិនត្រឹមត្រូវ ប៉ុន្តែយើងនាំនូវការពិភាក្សាស្ដីពីគំរូនៃសេចក្ដីក្លាហានរបស់បុរសអ្នកក្រដែលហ៊ានប្រឈមមុខជាមួយនឹងអ្នកមាន ហើយថែមទាំងតស៊ូព្យាយាមមិនរាថយ រហូតដល់បានទទួលនូវភាពយុត្តិធម៌ នេះជាគំរូដែលប្រកបដោយអំណាចខ្លាំងក្លាមែន ។ ការពិភាក្សាដែលគួរឲ្យចាប់អារម្មណ៍នេះអាចជួយជំរុញឲ្យមានការពិចារណាពីរបៀប ដែលបុរសអ្នកក្រនោះប្រើរបស់នៅក្នុងស្រុក ដែលជាធនធានតែមួយរបស់គាត់នោះដោយប្រើមានប្រសិទ្ធភាពនោះ គឺជាផ្លាំងដី!

រឿងមាយើង ទាក់ទងទៅនឹងសេចក្ដីយុត្តិធម៌ គឺពេលដែលជួបប្រទះនូវការសម្រេចចិត្តណាមួយរបស់អ្នកមានអំណាច ដែលមិន

[20] Luke 18:1-8

យុត្តិធម៌នោះ ។ តួនាទីឆ្នាំយាមទ្វាររាំងទាំងបួននាក់នោះគឺជាគំរូសំរាប់ការទាមទាររកយុត្តិធម៌ឲ្យអ្នកដទៃ ដែលយើងអាចលើកមកពិភាក្សា ដែលប្រកបដោយផលផ្លែនៅក្នុងសហគមន៍ ។ រឿងនេះអាចប្រើដើម្បីរកគំនិតថ្មី និងកម្លាំងនៃប្រាជ្ញារបស់ប្រពន្ធ ហើយការនោះអាចលើកឡើងពីចំណុចទូទៅទាក់ទងទៅនឹងភេទទាំងពីរ ។ ធនធានដ៏តិចតួចរបស់គ្រួសារក្រីក្រអាចជួយជំរុញឲ្យមានប្រសិទ្ធភាពក្នុងការសម្រេចបានលទ្ធផលយ៉ាងប្រសើរ ។ ប្រពន្ធជាអ្នកជួយលើកស្ទួយសមត្ថភាពប្ដីរបស់នាង ហើយប្ដីអាចយកទៅប្រើភ្លាមនូវអ្វី ដែលគាត់រៀនបានពីប្រពន្ធរបស់គាត់យ៉ាងមានលទ្ធផលល្អ ។ រឿងនេះទៅមុខទៀត អាចគូសបញ្ជាក់ពីសកម្មភាពវិវត្តរបស់ការរៀនដែលគេប្រើនៅក្នុងការអភិវឌ្ឍន៍សហគមន៍ (សកម្មភាព-គិតពិចារណា-រៀន-រៀបផែនការ-បញ្ចេញសកម្មភាព) ។

ខ្ញុំសង្ឃឹមថា អត្ថបទនេះនឹងជួយជំរុញ ហើយលើកទឹកចិត្តដល់គ្រឹស្តបរិស័ទខ្មែរ ដើម្បីឲ្យស្វែងរកមើលគុណតម្លៃ ដែលមាននៅក្នុងវប្បធម៌ដ៏សំបូរបែបរបស់ខ្លួន និងច្នៃប្រឌិតគុណតម្លៃទាំងនោះយកទៅប្រើក្នុងការផ្សាយដំណឹងល្អ ។

HONEYCOMB 4/1 (January 2003): 51–59



# Balancing Praying with Doing

*Russell H. BOWERS, Jr.*

Christians sometimes say, "If only we would pray, God would change our world." "Prayer meeting is the most important meeting of the week—the 'Hour of Power'." "Satan doesn't care what else we do, as long as we don't pray." All this implies that our talking to God outweighs God's talking to us (as we scrutinize the scriptures). It throws back into God's lap responsibilities he has assigned us. And it leads to a flurry of prayer and fasting vigils, seminars, and conferences.

Certainly prayer *is* essential. God *does* meet with us when we call on him. His Spirit aids our praying, unmasks our sins, breaks our pride, and draws us to Christ. God does answer prayer, and "is able to do immeasurably more than all we ask or imagine." But some people speak as if prayer were the whole of our responsibility—as if all we need do is pray and wait. That is wrong. Though prayer is *a* key to God's blessing, it is not the *only* key. Another is informed obedience.

Some people balk at that. Obedience sounds so pedestrian next to prayer. Isn't obedience a *human* work? Would not our efforts detract from the supernaturalness of revival? Would not God's glory

be dimmed if human contributions played a part? Are we talking synergism here?

So we bristle with Naaman and mutter, "I thought that he would surely come out to me and stand and call on the name of Yahweh his God, wave his hand over the spot and cure me. . . ." Naaman nearly forfeited his cure because he wanted to wait and watch God work, rather than participate by plunging into the Jordan. How we crave the passive (on our part) and the spectacular (on God's)!

But although there were times when God's people were to watch and do nothing (ask Jehoshaphat), there were others when God said, "Stop praying and start doing." This is the message we need today.

**Times to Stop Praying and Start Acting**

Joshua was leading Israel into Canaan. The nation had defeated Jericho, but lost at Ai. Israel's panicked leaders fell prostrate and prayed. Nothing wrong with that, but what did God say? "Stand up! What are you doing down on your face?" In brief God said, "*Stop praying*. Start acting. You have disobeyed. Correct the problem." Had Joshua insisted on continuing to *pray* when God said to *do*, Israel would have lost again. Do we ever substitute prayer for our nation or churches when there is obvious practical work that *we* should do?

Judah in Isaiah's day longed for revival. The nation prayed for it, but nothing happened. They wondered why.

> . . . [D]ay after day they seek me out;
>     they seem eager to know my ways,
> as if they were a nation that does what is right
>     and has not forsaken the commands of its God.
> They ask me for just decisions
>     and seem eager for God to come near them.
> 'Why have we fasted,' they say,
>     'and you have not seen it?
> Why have we humbled ourselves,
>     and you have not noticed?'

They prayed, but no revival followed. When they asked why, God told Isaiah to denounce their sin. If they would rise from their knees and obey him in their everyday relationships and responsibilities, God would answer. They needed to loose the chains of injustice, share their food with the hungry, do away with malicious talk, etc. These may not sound as "spiritual" as prayer vigils and fasts. They have to do with human actions and human relationships, not spectacular divine displays. But these, and not prayer, were the keys which would unlock revival:

> Then your light will break forth like the dawn,
> and your healing will quickly appear. . . .
> You will be like a well-watered garden,
> like a spring whose waters never fail.

Blessing for Judah would follow obedience, not more prayer and fasting.

We resist such counsel at our own peril. "Hear the word of Yahweh, all you people of Judah who come through these gates to worship Yahweh. This is what Yahweh Almighty, the God of Israel, says: *Reform your ways and your actions*, and I will let you live in this place." (Notice that God does not say, "Start a 24-hour prayer vigil," or "Go on a prolonged fast." He doesn't say, "Start praying to me," but "Start doing right to people.") "Do not trust in deceptive words and say, 'This is the temple of Yahweh, the temple of Yahweh, the temple of Yahweh!' If you really change *your ways and your actions* and deal with each other justly, . . . then I will let you live in this place. . . . But look, you are trusting in deceptive words that are worthless." These deceptive words suggested that Judah need not obey, but should instead continue to "worship." Unfortunately Judah ignored Jeremiah, and God sent Nebuchadnezzar to end their empty temple prayer meetings.

## Attempting to Give Back to God The Work He Gave Us

Does the same thing happen today? Do we ever pray when God tells us to act? Has any church ever tried to return to God the

responsibilities he has assigned to us? This, I suppose, would be the ultimate in "upward delegation."

For example, God commands us to evangelize. We invert that command and pray that *he* would do it—that he would somehow "open the hearts" of our neighbors while we say nothing to them. Perhaps we erect a church sign to inform passing sinners when we meet, but then fail to think up ways to creatively introduce them to Christ. There is nothing wrong with pleading for God's aid in our evangelism, but only if we plan to participate in the process. Or we "fulfill" our responsibilities to the sick and elderly by praying that God would comfort them, but ourselves neither call nor offer a meal. We pray that God would correct our nation's moral problems, yet write no protesting letters and watch the same videos as everybody else. We are commissioned to reach the world with the gospel, yet some churches tend to keep to themselves. God urges us to value our families and people and we chase things. Yet we pray for revival. What's wrong with this picture?

## Why Some People Prefer "Praying"

Why do we prefer prayer to action? One reason may be laziness. It is simply easier to open our mouths in windy prayer than to expend our lives in costly obedience. Actually building a house for a poor person is sweatier than praying that God house the needy. Finding out how best we can serve our neighbors, and then doing things for them that will open them to the gospel, exhausts us more profoundly than merely requesting that God speak to them, and then blindly plowing ahead with our Same Old Thing. Work is messier, too. When we struggle with people we make mistakes. We do things wrong, blunder up blind alleys, lose our patience, and drop the ball. We find ourselves needing to apologize and start over. We face criticism and ridicule. How much less traumatic and error-prone to instead intone orthodox prayers from our church buildings. We prefer prayer to obedience because of the *toil* of obedience.

A warning—good praying is also strenuous. Epaphras *wrestled* in prayer, and thus worked hard for the Asian churches. But while Epaphras worked hard at prayer he was surrounded by

those who worked hard at the *work*. The early church did not deceive itself into thinking prayer alone was the answer.

A second reason we prefer prayer to action is selfishness. Selfishness means I pursue my perceived best interest. Christianity, the church, people, and ultimately God, all exist to fulfill and make me comfortable. And while, in Christian charity, I am willing to pray that *God* bless others, *I* cannot reasonably be expected to sacrifice myself to help bring that blessing about. Prayer is cheaper; obedience costs too much.

Third, perhaps an inadequate loathing of sin blunts our urgency to obey God. We reduce sin to a theological concept—the reason why Christ came—and quote verses on its nature and consequences. Sin becomes only an abstract idea, not a concrete choice and terrible habit. But to God sin is not a tome on our theological shelves. It is a stench, and stirs his wrath and judgment. And while through the blood of Christ God forgives sin, we must learn to loath it, fear it, and run the other way. The church cannot dawdle in iniquity—either wrong things we do or right things we don't—and expect God to bless simply because we ask him to. If revival is what we want, certainly we will plead for it. But we will also in fear and faith obey the God who grants it.

A fourth reason we prefer prayer to action is that some people don't understand how important are the things we do. They think that if *humans* contribute to a ministry, it will detract from the glory of *God* in the fruit it bears. But that is not true. Rather than "Get out of the way and let God work," we must learn to "Get on board and do what God is doing." Paul did not think it was either God or us—he meant it when he called his team "God's fellow workers."

## God Uses People

Certainly God is not limited to using humans when he wants to do something. We served as neither consultants nor engineers when he made the world. God is sovereign; he is free to work when and how he chooses. But frequently and meaningfully God nevertheless does use people to accomplish his will.

Christians understand that the Bible is the word of God. The whole was breathed out by God. And while that is true, there is not a word of it that did not pass through the mind and flow from the pen of a man as well. *Paul* (not God) was the one who was on the verge of wishing himself cursed and cut off from Christ; *Jude* the person who was eager to write about salvation but felt compelled to address a different matter; *Luke* the individual who thought it good to write a gospel account, and so researched and composed it. The Bible is one hundred percent the word of God, but it is simultaneously one hundred percent the word of man. When God determined that humanity should have a written record of his will, he did not supernaturally float it down from the skies. Human beings struggled . . . and thought . . . and wrote . . . and sometimes rewrote. Through the centuries *God* has preserved that word as *people* copied, hid, carried, and translated it. Though he does not need to, God often accomplishes his work through people.

The humanity of Jesus is as essential to evangelical Christology as is his deity. Jesus was a man. We must remember that "the resurrection of the dead comes also through a *man* . . . there is one God and one mediator between God and men, the *man* Christ Jesus . . . he had to be made *like his brothers in every way*, in order that he might become a merciful and faithful high priest in service to God, and that he might make atonement for the sins of the people. . . ." God's salvation was not diluted by his using the *man* Jesus of Nazareth to accomplish it. On the contrary, salvation would have been impossible had that man not participated. Like the written word, the incarnate word is one hundred percent divine and one hundred percent human. Being human Christ could say, "I have set you an example that you should do as I have done for you." Eternal salvation is the work of God. But because Jesus is the savior it is also the work of a man—one who was like us in every way. God's glory is not diminished when he uses people—and their obedience and sacrifices—to accomplish his plan.

## Who Builds the Church?

By what means does the church grow today? Jesus said, "*I* will build my church." The book of Acts begins: "In my former book, Theolophilus, I wrote about all that *Jesus* began to do and to teach. . . ." This implies that Acts records what Jesus *continued* to do and to teach. But how does Jesus build his church? How does he continue to do and teach? Through people. Acts records some of their sailings . . . struggles . . . sermons . . . and sufferings. Paul told the Colossians, "I fill up in my flesh what is still lacking in regard to Christ's afflictions for the sake of his body, which is the church. . . . I want you to know how much I am struggling for you. . . ." Acts says that *Christ* was building the Colossian church. Colossians says that *Paul* was building the Colossian church. How do these two fit together? Christ was building the church through Paul. God does his work through people. And Christ builds his church today as *people* obey him—choose not to get out of his way, but rather get on board and do what he is doing. No church is built without the evangelism, teaching, giving, serving, and labor of people . . . as they are motivated and empowered by the spirit of God. The church grows and builds itself up in love *as each part does its work*, not as each part sits and waits for God to do his work. It is simultaneously the work of God and people.

The same with revival. Sure we need to pray for it. But we also need to work for it. Our work does not detract from God's work, or diminish his glory when the answer comes. God often does his work *through people*. So we need more calls for the church to quit the monastery and obey God in the marketplace. When we are busy practicing daily righteousness

> Then [our] light will break forth like the dawn,
> and [our] healing will quickly appear. . . .
> [We] will be like a well-watered garden,
> like a spring whose waters never fail.

Pentecost is not going to be repeated; there is no need to pray for that to happen. The church already stands "clothed with power from on high." We need more calls to take the tasks we have been given and fulfill them in the strength God provides.

## What Does God Want?

Christianity is not that complicated. Does the Almighty crave our self-denying ritual? The prophet ponders that question:

With what shall I come before Yahweh
and bow down before the exalted God?
Shall I come before him with burnt offerings,
with calves a year old?
Will Yahweh be pleased with thousands of rams,
with ten thousand rivers of oil?
Shall I offer my firstborn for my transgression,
the fruit of my body for the sin of my soul?
He has showed you, O man, what is good.
And what does Yahweh require of you?
To act justly and to love mercy
and to walk humbly with your God.

Micah's conclusion is simple. God does not seek our prolonged prayers or extended fasts. He is not as impressed with showy display as he is with daily obedience. Similarly, the answer to the psalmist's question, "Yahweh, who may dwell in your sanctuary?" doesn't mention religious ritual, but instead discusses practical, daily righteousness. When people asked John the Baptist, "What should we do?" he answered mundanely: "Donate your excess, act honestly, be content." Nothing spectacular or "religious" here. Yet God would bless if people obeyed.

How often do we say, "I'll pray for you," when what we need to say is, "Let me help you"? Prayer is not the end of our responsibility but the beginning: it opens the door for God to direct and strengthen us for our tasks. However one may assess her theology, Mother Theresa did more through her deeds to make Christianity and Christ respectable in non-Christian India than do the genuflections of thousands who may think more biblically but who do nothing. "Dear children, let us not love"—or seek revival, or attempt to win the lost—"with words or tongue but with actions and in truth."

Doubtless our nation needs God's hand upon us. Certainly we should pray for that. But no less surely we need to be doing what God has commanded. We need to rise from our knees and go with

our feet, help with our hands, speak with our tongues, and embrace with our arms. Prayer is *a* key to revival, but so is obedience. God answers, but he often answers through people. Perhaps his answer will include us. May we not be guilty of sitting and sighing, "I wish *God* would do something," while all the time ignoring the God who says, "I wish *you* would do something."

សំណាំទឹកឃ្មុំ ៤/១ (មករា ២០០៣)៖ ៦០-៧៤



# ការថ្លឹងថ្លែងសេចក្តីអធិស្ឋាន ជាមួយការប្រព្រឹត្តិ

*រ៉ាស់សែល បាទខ្ទីស៍*

ពេលខ្លះគ្រីស្ទាននិយាយថា “ប្រសិនបើយើងអាចអធិស្ឋានមែន ព្រះមុខជាអាចផ្លាស់ប្តូរពិភពលោកយើង ។ ការប្រជុំអធិស្ឋានគឺជាការប្រជុំសំខាន់បំផុតនៅក្នុងសប្តាហ៍ - ‘ម៉ោងនៃបុទ្ធានុភាព’ ។ សាតាំងមិនខ្វល់នូវអ្វីដែលយើងធ្វើទេ បើយើងមិនអធិស្ឋាន” ។ ការទាំងអស់នេះសបញ្ជាក់ឲ្យឃើញថា ការដែលនិយាយទៅរកព្រះសំខាន់ជាងការដែលព្រះមានបន្ទូលមករកយើង នៅពេលដែលយើងសិក្សាព្រះបន្ទូលទ្រង់ ។ វាបង្វិលការខ្លះដែលទ្រង់ចង់ឲ្យយើងធ្វើទៅទំលាក់លើព្រះអង្គវិញ ។ ហើយនាំយើងទៅរកការរំភើបនៃការអធិស្ឋាន និងពិធីតម សិក្ខាសាលា និងសន្និសីទនានា ។

ការអធិស្ឋានដែលពិតប្រាកដគឺជាសារៈសំខាន់ ។ ព្រះជួបជាមួយយើងនៅពេលដែលយើងអំពាវនាវរកព្រះអង្គ ។ ព្រះវិញ្ញាណរបស់ទ្រង់ជួយក្នុងការអធិស្ឋានរបស់យើង ផ្តាច់រនាំងបាបរបស់យើង បំបាក់អំនួត និងនាំយើងទៅរកព្រះគ្រីស្ទ ។ ព្រះឆ្លើយតបការអធិស្ឋាន និង “អាចធ្វើ

ទហើយធ្ងអក្ពុតាល„ ធ្រលទឹកទសេះយើលក្ចុលយរម្រែុះឪផ្ទុទីវុមទស (ម្រុហម
ហ៊ែគារ នយ៉ះយើលគ្នី) លុអផ្ទុវម្ពិត្តីរគ្នុយទន្ធគាភ្យេរ្ធផ្ទុះប្រុះយើលុមល៖
ស៊ើយែលក្ចុលយរះឪលយរទស គាភ្យេរម្ហយាបផ្ទុយ្ហុគល្ហះសៅទីវុល្ន៉ុ
៲ (ះយើលុមល៖មហបរុក្ខ)
ែ៖ហើមអក្ខបយេគាទ្ធលែមនផ្ទុទ្ធ (ផ្ទុគ្គារលុមល៖មហបរុក្ខ) លុហៅលែលព
លនីនធ្រុគគ្រីមរប្រុរផ្ទុលផ្ទុគ្គារម្ហរ ៲ ទុភ្យេ៖ណេទីរនផ្ទុមឺ្របរលឌិមហេរគាភ្យេរ
គនែលឌិមុយេផ្ទុយ្ហុ ៖យេធ្គិរះយើលន្ហរធ្រុផ្ទុ៖មុយេះយើរគាភ្យេរ មុយេលុមល៖
មយរប្ហុ៖យេផ្ទុលមុយខ្មិត្ថិរផ្ទុទ្ធមរុលប្រែរទុស្ហុយាប ៲ „…ប្រុទយផ្ទុពិ
មយរខ្មិរុប្តរក្ខល្ហរប្ហក្ខុបគាប្ហរ មហេរទរុះយើប្រុហ៊ែគារះយើគផ្ទះយើលុក្ខ
៖ប្រេ៖យេអុពេល យ៉ែអផុមគយ៉ែឈរផ្ទុទ្ធមហេរប្រុក្ខមយើធ្រុទយ៉ើយ៉ែអលន្ហរ„
ធ្រុគាហេទ្ធគាភ្យេរទុស្ហុយាបគាគីប្រុគរផ្ទុប្ហមុទសផ្ទុគ្គារម្ហរ ះឈិរក្ខិ
៖ព៉ះទរន្ហម៉ហរមីន្ធទ្ធផ្ទុប្រែរប្ហអុគាហេទ្ធផ្ទុប៉ម្ហ
ផ្ទុគ្គារម្ហរ ៖ះប្រេរផ្ទុមឺ្របរមហបរុក្ខទសលែម៉គលុមល៖ម្ហ៊ីឬលើ៖យេល្ហរទលុលិ
ព៉នរលុអេលើយេប្រុររគាយ៉ើទន្ធះយើលុមល៖ព៉ើ៖ល្ហមុហ្ហរ ៖ហេបយ៉ើ៖ប្រុផ្ទុខេយ៉ែ៖
ផ្ទុន្ហែរលុ៖ខ្មិត្ថិរ៖យេទរុម្ហប្រុគិឌប្ហលុល្ហររែ៖ហើមអបយេប្ហយ៉ែឈរម្ហីន្ធលុរនខ្មិត្ថិរ
លក្ចុព៉នរផ្ទុគ្គារលុមល៖ម្ហីឬលើ៖យេប្រុទគរុទន្ធម្ហរ ៖អ្ហព៉នរភ្យេរុលែម៉គលុមល៖
ម្ហីឬលើ៖យេប្រុទគរុទន្ធលុត្ថើណលុហើម៖យេម្ហរ ៲ ទហើយធ្ងអ៖យេម្ហលុងើល៖ហេគខ្ចី
មុយប្រុគក្ខិល្ហមុយាលុត្ថើណលុហើម៖យេ ៲ ះទរ៖យេម្ហអុផ្ទុល៖លេគ្ហរះឪមអិ
៲ លុត្ថើណលុហើម៖យេម្ហ ះយេរម្រែុរគាគីហេរទមិ ៲ នរះយេរមុយគាគីមរុ
ហេរទមិប្រុទគរុទន្ធបុ គាភ្យេរម្ហះយើលុមល៖យេះយើម៖ស្រុះង៉េរហេរទមិ
ប្រុម្ហ ទហើយធ្ងអ៖យេប្រុល្ហះសៅ ¡គាប្ហរលុខ៉ផ្ទុគ្ហអ្ហមុម្ហ ៲ ធ្រុផ្ទុ៖គាប្ហរ ទហើយធ្ងអ
មរុទុយេប្ផុគ្គារប្រុគក្ខិល្ហមុយា – ផ្ទុគ្គារលុមល៖៖ម្ហើលេខ៉លនីន៖យេះយរព្ហ
គាប្ហរទុយេលុមើ៖យេប្រុម្ហទហើយធ្ងអ៖យេ ធ្រុមម្ហគាភ្យេរះទរផ្ទុទីវុមគម្ហើលុគាល
ផ្ទុគះឪមអិទីវុល្ន៉ុ ៲ „មក្រែររុរមម្ហគាប្ហរ គលិមផ្ទុគ្គារលក្ចុអ្ហិផ្ទុប្រុលុល្ហរទយ

ហើយចាប់ផ្តើមធ្វើការ" ។ នេះគឺជាព្រះបន្ទូលដែលយើងត្រូវការនៅថ្ងៃនេះ ។

## ពេលដែលយើងត្រូវឈប់អធិស្ឋាន ហើយចាប់ផ្តើមធ្វើសកម្មភាពវិញ

យ៉ូស្វេបានដឹកនាំអ៊ីស្រាអែលចូលទឹកដីសន្យា ។ ពួកគេបានយកជ័យជំនះលើទីក្រុងយេរេខូ ប៉ុន្តែបរាជ័យនៅទីក្រុងអៃ ។ ពួកអ៊ីស្រាអែលមានការភ័យញ័រ អ្នកដឹកនាំមានអារម្មណ៍អស់សង្ឃឹម ហើយពួកគេបានអធិស្ឋាន ។ គ្មានអ្វីដែលខុសទេចំពោះការនេះ ប៉ុន្តែតើអ្វីដែលព្រះទ្រង់មានបន្ទូល? សរុបឲ្យខ្លីព្រះមានបន្ទូលថា "ឈប់អធិស្ឋាន ។ បញ្ចេញសកម្មភាពវិញ ។ ឯងបានមិនស្តាប់បង្គាប់ ។ កែប្រែបញ្ហា" ។ តើយ៉ូស្វេនៅតែទាមទារអធិស្ឋានទៀតដែរទេឬអី នៅពេលដែលព្រះមានបន្ទូលឲ្យធ្វើ បើគេនៅតែធ្វើយ៉ាងដូច្នេះនោះគេនឹងមានការបរាជ័យជាថ្មីម្តងទៀត ។ តើយើងអាចដាក់ជំនួសការទូលអង្វរសំរាប់ជនជាតិ ឬពួកជំនុំរបស់យើងដោយអនុវត្តការងារសំខាន់ជាក់ស្តែងបាន ឬទេ?

យូដានៅក្នុងសម័យអេសាយអំពាវនាវសូមឲ្យមានការធ្វើឲ្យរីកផុសផុលខាងវិញ្ញាណ ។ ជនជាតិទាំងអស់អធិស្ឋានសំរាប់ការនេះ ប៉ុន្តែគ្មានការអ្វីកើតឡើងឡើយ ។ ពួកគេឆ្ងល់ថា ហេតុអ្វីបានជាយ៉ាងនេះ ។

.......រាល់តែថ្ងៃគេស្វែងរកអញជានិច្ច ហើយពេញចិត្តចង់ស្គាល់ផ្លូវរបស់អញ ទុកដូចជាសាសន៍ណាមួយដែលប្រព្រឹត្តដោយសុចរិត ឥតបោះបង់ចោលសេចក្តីយុត្តិធម៌របស់ព្រះនៃគេឡើយ គេសូមសេចក្តីវិនិច្ឆ័យដ៏សុចរិតពីអញ គេរីករាយចិត្តដោយចូលទៅជិតព្រះ គេពោលថា យើងតមអត់ ហេតុអ្វីបានជាទ្រង់មិនឃើញសោះ យើងខ្ញុំបានបញ្ឈឺចិត្តខ្លួន ហេតុអ្វីបានជាទ្រង់មិនយកចិត្តទុកដាក់ដូច្នេះ?

ពួកគេអធិស្ឋាន ប៉ុន្តែគ្មានការធ្វើឲ្យរស់ឡើងវិញខាងឯវិញ្ញាណកើតមានឡើងឡើយ ។ ពេលដែលពួកគេសួរថា ហេតុអ្វីបានជាព្រះមានបន្ទូលទៅអេសាយឲ្យពួកគេប្រកាសបដិសេធអំពើបាបរបស់គេ ។ ប្រសិនបើគេងើបឡើងពីការអធិស្ឋាន ហើយស្តាប់បង្គាប់នៅរាល់ទំនាក់ទំនង និងការទទួលខុសត្រូវប្រចាំថ្ងៃរបស់ពួកគេ នោះព្រះនឹងឆ្លើយតប ។ ពួកគេត្រូវតែកាច់បំបាក់នូវច្រវាក់នៃភាពអយុត្តិធម៌ ចែកចាយអាហារដល់អ្នកឃ្លាន ងាកចេញពីសំដីព្យាបាទគេ ។ល។ ទាំងនេះហាក់មិនសូវដូចជា "ភាពខាងឯវិញ្ញាណ" ដូចជាពិធីអធិស្ឋាន និងការតមនោះទេ ។ គឺមានការធ្វើជាមួយសកម្មភាពរបស់មនុស្ស និងទំនាក់ទំនងរបស់មនុស្ស មិនមែនជាការបង្ហាញទស្សនិយភាពដ៏អស្ចារ្យរបស់ព្រះនោះទេ ។ ប៉ុន្តែទាំងអស់នេះមិនមែនការអធិស្ឋានឡើយដែលជាកូនសោដើម្បីបើកឲ្យមានការធ្វើឲ្យរស់ឡើងវិញខាងឯវិញ្ញាណៈ យ៉ាងនោះទើបពន្លឺរបស់ឯងនឹងលេចមកដូចជារស្មីអរុណ ហើយសេចក្តីសុខស្រួលរបស់ឯង នឹងលេចឡើងជាយ៉ាងឆាប់...ឯងនិងបានដូចជាសួនច្បារដែលគេស្រោចទឹក ហើយដូចជាក្បាលទឹកដែលមិនខានហូរឡើយ ។ ព្រះពរសំរាប់យូដាគឺកើតឡើងតាមការស្តាប់បង្គាប់ មិនមែនការអធិស្ឋាន និងតមអាហារថែមទៀតនោះទេ ។

យើងបដិសេធយោបល់បែបនេះទាំងប្រថុយប្រថាន ។ "ចូរស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ ឱ អស់អ្នកក្នុងពួកយូដា ដែលចូលទៅថ្វាយបង្គំព្រះយេហូវ៉ាតាមទ្វារទាំងនេះអើយ ព្រះយេហូវ៉ានៃពួកពលបរិវារជាព្រះនៃសាសន៍អ៊ីស្រាអែលទ្រង់មានបន្ទូលដូច្នេះថា ចូរកែផ្លូវប្រព្រឹត្តនិងចរិតរបស់ឯងរាល់គ្នាឲ្យល្អវិញចុះ នោះអញនឹងឲ្យឯងរាល់គ្នាអាស្រ័យនៅទីនេះតទៅ" ។ (សូមកត់សំគាល់កន្លែងនេះ ព្រះមិនបានមានបន្ទូលយ៉ាងដូច្នេះទេថា "ចាប់ផ្តើមធ្វើពិធីអធិស្ឋាន២៤ម៉ោង" ឬ "បន្តតមឲ្យកាន់តែ

យូរថ្ងៃថែមទៀត" នោះទេ ។ ទ្រង់ក៏មិនបានបន្ទូល យ៉ាងដូច្នេះដែរថា "ចាប់ផ្តើមអធិស្ឋានមកឯអញ" ប៉ុន្តែទ្រង់បែរជាមានបន្ទូលថា "ចាប់ផ្តើមប្រព្រឹត្តសុចរិតនៅចំពោះមនុស្ស" វិញ) ។ "កុំឲ្យទុកចិត្តនឹងពាក្យកំភូតឡើយ ដោយនិយាយថា "នេះជាព្រះវិហារនៃព្រះ យេហូវ៉ា ជាព្រះវិហារនៃព្រះយេហូវ៉ា ជាព្រះវិហារនៃព្រះយេហូវ៉ា" ។ ដ្បិតបើអ្នករាល់គ្នាកែផ្លូវប្រព្រឹត្ត និងចរិតឯងឲ្យល្អ ហើយបើសំរេចក្តីដល់មនុស្ស និងជិតខាងដោយយុត្តិធម៌...នោះអញនឹងឲ្យឯង អាស្រ័យនៅទីនេះតទៅ...។ មើលឯងរាល់គ្នាទុកចិត្តនឹងពាក្យកំភូត ដែលនឹងមានប្រយោជន៍មិនបាន" ។ ពាក្យកំភូតទាំងអស់នេះ បាននិយាយថា យូដាមិនត្រូវការស្តាប់បង្គាប់ទេ ប៉ុន្តែពួកគេនៅតែបន្ត "ថ្វាយបង្គំ" ។ គួរឲ្យសោកស្តាយ យូដាបានបដិសេធយេរេមា ហើយព្រះបានបញ្ជូននេប៊ូក្នេសាមកបញ្ចប់ការជួបជុំអធិស្ឋានដ៏រាក់កំផែលនៅក្នុងព្រះវិហារ ។

## ព្យាយាមប្រគល់ត្រឡប់ទៅវិញដល់ព្រះនូវកិច្ចការ ដែលទ្រង់បានប្រគល់ឲ្យយើង

តើការដូចគ្នានេះកើតឡើងសព្វថ្ងៃនេះដែរទេឬអី? តើយើងនៅតែអធិស្ឋាននៅពេលដែលព្រះប្រាប់យើងឲ្យបញ្ចេញសកម្មភាព? តើមានពួកជំនុំណាដែលធ្លាប់ព្យាយាមប្រគល់ទៅព្រះវិញនូវការទទួលខុសត្រូវដែលទ្រង់បានប្រគល់ឲ្យយើងធ្វើ? នេះគឺជាការដែលខ្ញុំគិតថាជា "ការផ្ទេរសិទ្ធិអំណាចទៅខាងលើ" ដ៏ពិតប្រាកដ ។

ឧទាហរណ៍ ព្រះបញ្ជាឲ្យយើងផ្សាយដំណឹងល្អ ។ យើងបង្វិលព្រះរាជបញ្ជារបស់ព្រះអង្គដោយគ្រាន់តែអធិស្ឋានសូមឲ្យព្រះអង្គធ្វើការនោះ - សូមព្រះអង្គ "បើកចិត្ត" អ្នកជិតខាងរបស់យើង ដោយយើងមិនបាច់និយាយអ្វីទាំងអស់ដល់ពួកគេ ។ ប្រហែលជាយើងតម្លើងផ្លាក

ព្រះវិហារឲ្យត្រង់ឡើងលើដើម្បីផ្តល់ដំណឹងដល់មនុស្សមានបាបដែលដើរកាត់នៅពេលដែលយើងជួប ប៉ុន្តែយើងបរាជ័យមិនបានណែនាំពួកគេឲ្យស្គាល់ព្រះគ្រីស្ទ ។ មិនមានអ្វីខុសក្នុងការដែលអង្វរសូមជំនួយមកអំពីព្រះអង្គក្នុងការផ្សាយដំណឹងល្អរបស់យើងនោះទេ ឲ្យតែយើងមានគំរោងការដើម្បីចូលរួមនៅក្នុងដំណើរការនោះដែរ ។ ឬយើង "បំពេញ" ការទទួលខុសត្រូវរបស់យើងដល់អ្នកឈឺ និងចាស់ជរាដោយអធិស្ឋានសូមឲ្យព្រះទ្រង់កំសាន្តចិត្តពួកគេ ប៉ុន្តែខ្លួនយើងវិញមិនទាំងដែលសួរសុខទុក្ខ និងផ្តល់អាហារដល់ពួកគេផងនោះ ។ យើងអធិស្ឋានដើម្បីសូមឲ្យព្រះអង្គកែតំរង់អំពីបញ្ហាសីលធម៌របស់ជនជាតិយើង ប៉ុន្តែមិនបានសរសេរសំបុត្រតវ៉ា និងថែមទាំងមើលរឿងវីដេអូដូចដែលពួកគេគ្រប់គ្នាមើលដែរ ។ យើងត្រូវបានបញ្ជូនឲ្យទៅឈោងចាប់ពិភពលោកតាមរយៈដំណឹងល្អ តែមានពួកជំនុំមួយចំនួនបែរជាគិតតែពីខ្លួនឯង ។ ព្រះជំរុញយើងឲ្យផ្តល់តម្លៃដល់គ្រួសារ និងប្រជាជនរបស់យើង និងដេញចាប់ការទាំងអស់នោះ ប៉ុន្តែយើងបែរជាអធិស្ឋានសំរាប់ការរីកផុសផុលទៅវិញ ។ តើមានអ្វីខុសចំពោះរូបភាពនេះ?

## ហេតុអ្វីបានជាមនុស្សមួយចំនួនចូលចិត្តអធិស្ឋានច្រើនជាង

ហេតុអ្វីបានជាយើងចូលចិត្តអធិស្ឋានច្រើនជាងការបញ្ចេញសកម្មភាព? ហេតុផលទីមួយប្រហែលជាភាពខ្ជិល ។ វាប្រហែលជាមានការងាយស្រួលជាងក្នុងការដែលគ្រាន់តែបើកមាត់របស់យើងអធិស្ឋានក្នុងខ្យល់ ជាជាងចំណាយជីវិតរបស់យើងទៅក្នុងតម្លៃនៃការស្តាប់បង្គាប់ ។ តាមពិតទៅការសង់ផ្ទះសំរាប់អ្នកក្រ គឺបែកញើសជាងគ្រាន់តែអធិស្ឋានសូមឲ្យព្រះប្រទានផ្ទះដល់អ្នកដែលត្រូវការ ។ ការដែលស្វែងរកយ៉ាងណាដែលជាការប្រសើរដើម្បីបំរើដល់អ្នកជិតខាងរបស់យើងហើយ

ធ្វើការសំរាប់ពួកគេដើម្បីបើកផ្លូវពួកគេនាំទៅរកជំណឿងល្អ ធ្វើឲ្យយើងមានការហត់នឿយខ្លាំងជាង បើគ្រាន់តែសូមឲ្យព្រះមានបន្ទូលទៅរកពួកគេ ហើយបន្ទាប់មកទុកវាចោលដោយមិនបាច់ធ្វើអ្វីសោះ ។ ការងារមានការច្របូកច្របល់ដែរ ។ នៅពេលដែលយើងខំប្រឹងប្រែងដោះស្រាយជាមួយមនុស្សយើងបង្កើតកំហុស ។ យើងធ្វើការខ្វះខុស បង្កើតកំហុសដោយច្រកងងឹត បាត់បង់ភាពអត់ធ្មត់ ហើយលះបង់ចោល ។ យើងយល់ឃើញថា ខ្លួនយើងត្រូវការនិយាយសូមទោស ហើយចាប់ផ្តើមការងារម្តងទៀត ។ យើងជួបការរិះគន់ និងការចំអកឡកឡឺយ ។ តើអាចបន្ថយការភ័យស្លុត និងឆាប់មានកំហុសយ៉ាងណាបាន បើសិនជាយើងគ្រាន់តែលើកដាក់សម្លេងរបស់យើងតែក្នុងសេចក្តីអធិស្ឋានសំរាប់អាគារព្រះវិហាររបស់យើងនោះ ។ យើងចង់តែអធិស្ឋានជាងការស្តាប់បង្គាប់ដោយព្រោះតែការស្តាប់បង្គាប់ជាកិច្ចការលំបាកធ្ងន់ធ្ងរ ។

ការដាស់តឿន - ការអធិស្ឋានល្អគឺក៏ជាកម្លាំងខ្លាំងក្លាដែរ ។ អេប៉ាប្រាសបានមានបញ្ហានៅក្នុងការអធិស្ឋាន ហើយដូចគ្នាដែរក៏ធ្វើការយ៉ាងខ្លាំងក្លាសំរាប់ពួកជំនុំអាស៊ី ។ ប៉ុន្តែក្នុងខណៈដែលអេប៉ាប្រាស បានធ្វើការយ៉ាងធ្ងន់ធ្ងរជាមួយការអធិស្ឋាន គាត់ចាប់ផ្តើមមានសុទ្ធតែមនុស្សធ្វើការយ៉ាងសកម្មនៅឯការងាររបស់គាត់ ។ ពួកជំនុំដំបូងមិនបានត្រូវបោកបញ្ឆោតនៅក្នុងគំនិតគិតតែពីអធិស្ឋានតែមួយដែលជាចម្លើយនោះទេ ។

ហេតុផលទីពីរ យើងចូលចិត្តអធិស្ឋានជាងការបញ្ចេញសកម្មភាព គឺជាភាពអាត្មានិយម ។ ភាពអាត្មានិយមមានន័យថា ការខំប្រឹងប្រែងសំរាប់ការចាប់អារម្មណ៍ខ្លួនឯង ។ គ្រីស្ទបរិស័ទ ពួកជំនុំ មនុស្ស ហើយចុងក្រោយនោះ គឺព្រះជាម្ចាស់គ្រប់របស់ទាំងអស់មានឡើងដើម្បីបំពេញ និងសំរាប់តែធ្វើឲ្យខ្លួនយើងមានភាពស្រណុកស្រួលតែ

ប៉ុណ្ណោះ ។ ហើយនៅក្នុងខណៈពេលដែលត្រូវចែកទានដល់អ្នកក្រីក្រ ខ្ញុំស្ម័គ្រចិត្តអធិស្ឋានដើម្បីឲ្យព្រះប្រទានពរដល់អ្នកដទៃ ខ្ញុំមិនអាចមានហេតុផលណាដែលសង្ឃឹមថានឹងលះបង់ខ្លួនខ្ញុំដើម្បីនាំព្រះពរចេញទៅក្រៅនោះទេ ។ ការអធិស្ឋាន គឺថោកជាង ចំណែកឯការស្តាប់បង្គាប់ត្រូវបង់តម្លៃយ៉ាងច្រើន ។

ទីបីប្រហែលភាពស្ទាក់ស្ទើរមិនពេញលក្ខណៈរបស់អំពើបាបបង្អាក់យើងមិនឲ្យស្តាប់បង្គាប់ភ្លាមៗបាន ។ យើងកាត់បន្ថយអំពើបាបឲ្យទៅជាទស្សនៈបែបទេវវិទ្យាទៅវិញ - មូលហេតុដែលព្រះគ្រីស្តយាងមក - ហើយលើកខគម្ពីរបញ្ជាក់ពីលក្ខណៈ និងផលវិបាកនៃទស្សនៈនោះ ។ បាបគ្រាន់តែក្លាយទៅជាគំនិតអរូបីតែប៉ុណ្ណោះ មិនមែនជាការជ្រើសរើសដ៏រឹងមាំ និងទំលាប់អាក្រក់ទេ ។ ប៉ុន្តែចំពោះព្រះវិញ បាបមិនមែនជាកំណត់នៅក្នុងទូដាក់សៀវភៅទេវវិទ្យារបស់យើងទេ ។ វាជាក្លិនស្អុយហើយកកូរព្រះពិរោធ និងការជំនុំជំរះរបស់ទ្រង់ ។ ហើយតាមរយៈព្រះលោហិតព្រះគ្រីស្ត ទ្រង់អត់ទោសបាបឲ្យ យើងត្រូវតែរៀនពីភាពស្ទាក់ស្ទើរ ខ្លាច និងរត់គេចទៅផ្លូវដទៃទៀត ។ ពួកជំនុំមិនត្រូវតំអក់នៅក្នុងអំពើទុច្ចរិតទេ ទោះបីជាការខុសដែលយើងធ្វើ ឬការត្រឹមត្រូវដែលយើងមិនធ្វើហើយសង្ឃឹមថា ព្រះនឹងប្រទានពរដោយព្រោះតែយើងបានសូមព្រះអង្គដែរ ។ ប្រសិនបើការរីកផុលផុស ជាការដែលយើងចង់ពិតប្រាកដហើយយើងនឹងសូមសំរាប់វា ។ ប៉ុន្តែយើងនឹងស្ថិតនៅក្នុងការកោតខ្លាច និងជំនឿផងដែរ ក្នុងការស្តាប់បង្គាប់ព្រះដែលជាអ្នកដែលផ្តល់មកឲ្យយើង ។

ហេតុផលទីបួនការដែលយើងចង់អធិស្ឋានជាងការបញ្ចេញសកម្មភាពគឺដោយព្រោះមនុស្សខ្លះមិនយល់ថា តើការដែលយើងប្រព្រឹត្តមានសារៈសំខាន់ប៉ុណ្ណា ។ ពួកគេគិតថា ប្រសិនបើមនុស្សមានចំណែក

នៅក្នុងព័ន្ធកិច្ច នោះមានការរំខានដល់សិរីល្អរបស់ព្រះនៅក្នុងផលដែលបង្កើតឡើង ។ ប៉ុន្តែនេះមិនមែនជាការពិតទេ ។ ជាជាង "ចេញឲ្យឆ្ងាយទៅទុកឲ្យព្រះជាអ្នកធ្វើ" យើងត្រូវតែរៀនដូចការនេះវិញ "ចូលមកក្នុងជួរហើយធ្វើអ្វីដែលព្រះកំពុងធ្វើ" ។ លោកប៉ុលមិនបានគិតថា ការនេះជាចំណែកព្រះ ឬចំណែកយើងឡើយ នៅពេលដែលគាត់និយាយថា ក្រុមរបស់គាត់គឺគាត់មានន័យថា "បងប្អូនរួមការងារក្នុងព្រះ" ។

## ព្រះប្រើមនុស្ស

ពិតប្រាកដហើយ ព្រះគ្មានព្រំដែនឡើយក្នុងការប្រើមនុស្សនៅពេលដែលទ្រង់សព្វព្រះហឫទ័យចង់ធ្វើកិច្ចការអ្វីមួយ ។ យើងមិនបានបំរើដូចជាអ្នកប្រឹក្សា ឬជាវិស្វករនៅពេលដែលទ្រង់បង្កើតពិភពលោកទេ ។ ទ្រង់មានអំណាចអស្ចារ្យ ទ្រង់មានសេរីភាពក្នុងការធ្វើការគ្រប់ពេល និងជ្រើសរើសនរណាម្នាក់យ៉ាងណាក៏បានដែរ ។ ប៉ុន្តែជាទូទៅ និងមានន័យបំផុត គឺព្រះប្រើមនុស្សដើម្បីសំរេចបំណងព្រះហឫទ័យរបស់ព្រះអង្គ ។

គ្រីស្ទបរិស័ទយល់ថា ព្រះគម្ពីរគឺជាព្រះបន្ទូលព្រះ ។ ព្រះគម្ពីរទាំងមូលនេះត្រូវបានព្រះបណ្តាលឲ្យតែងឡើង ។ ហើយក្នុងពេលដែលការនោះជាសេចក្តីពិត គឺគ្មានពាក្យមួយម៉ាត់ណាដែលមិនបានឆ្លងកាត់តាមរយៈគំនិត និងមនុស្សដូចគ្នាដែរ ។ លោក ប៉ុល (មិនមែនព្រះទេ) គឺជាម្នាក់ដែលខ្លួនគាត់ផ្ទាល់ស្ទើរតែសូមឲ្យព្រះដាក់បណ្តាសា និងកាត់គាត់ចេញពីព្រះអង្គ ។ លោកយូដាជាអ្នកដែលឆេះឆួលក្នុងការសរសេរអំពីសេចក្តីសង្គ្រោះ ប៉ុន្តែបានមានអារម្មណ៍បង្ខំឲ្យសរសេរពីរឿងផ្សេងទៅវិញ ។ លោកលូកាជាបុគ្គលម្នាក់ដែលបានគិតថាជាការល្អក្នុងការសរសេររឿងដំណឹងល្អ ហើយបន្ទាប់មកគាត់បានធ្វើការស្រាវជ្រាវ ហើយក៏សរសេរឡើង ។ ព្រះគម្ពីរគឺជាព្រះបន្ទូលព្រះមួយរយភាគរយ ប៉ុន្តែក្នុង

ពេលជាមួយគ្នាដែរជាពាក្យរបស់មនុស្សមួយរយភាគរយ ។ នៅពេលដែលព្រះយល់ថាមនុស្សគួរតែកត់ត្រាពីបំណងព្រះហឫទ័យរបស់ព្រះអង្គ គឺទ្រង់មិនបានទំលាក់វាចុះពីមេឃក្នុងភាពអស្ចារ្យនោះទេ ។ នៅពេលដែលមនុស្សជួបឧបសគ្គ... ហើយគិត... ហើយសរសេរឡើង និងពេលខ្លះសរសេរម្តងទៀត ។ ទោះបីជាមនុស្សបានចម្លង លាក់ទុក នាំចេញទៅ និងបកប្រែវាយ៉ាងណាក៏ដោយ ជាច្រើនសតវត្សកន្លងមកនេះព្រះបានរក្សាព្រះបន្ទូលនេះនៅតែដដែល ។ ទោះបីជាព្រះអង្គមិនត្រូវការក៏ដោយ ប៉ុន្តែព្រះអង្គតែងតែសំរេចកិច្ចការតាមរយៈមនុស្ស ។

មនុស្សភាពក៏ដូចជាទេវភាពរបស់ព្រះយេស៊ូដែរ គឺមានសារៈសំខាន់ដូចគ្នាដល់ព្រះគ្រីស្តវិទ្យា (ការសិក្សាអំពីព្រះគ្រីស្ត) របស់អ្នកដឹកនាំដំណឹងល្អ ។ ព្រះយេស៊ូគឺជាមនុស្ស ។ យើងត្រូវតែចងចាំថា "នោះសេចក្តីដែលមនុស្សស្លាប់រស់ឡើងវិញ គឺមកតាមរយៈមនុស្សដែរ...មានព្រះតែមួយ ហើយអ្នកបង្រួបបង្រួមតែមួយនៅកណ្តាលព្រះនិងមនុស្ស គឺជាមនុស្សដ៏ជាគ្រីស្តយេស៊ូនោះ...ហេតុនោះបានជាគួរឲ្យទ្រង់ដូចបងប្អូនទ្រង់គ្រប់ជំពូកដែរ ដើម្បីឲ្យបានធ្វើជាសំដេចសង្ឃដែលមានសេចក្តីមេត្តាករុណា ហើយក៏ស្មោះត្រង់ក្នុងការទាំងប៉ុន្មានខាងឯព្រះប្រយោជន៍នឹង ថ្វាយដង្វាយឲ្យធួននិងបាបរបស់ប្រជាជនទាំងឡាយ..." ។ សេចក្តីសង្គ្រោះរបស់ព្រះមិនមែនទៅជាខ្សោយកម្លាំងក្នុងការប្រើព្រះយេស៊ូជាអ្នកភូមិណាសារ៉ែតដើម្បីសំរេចកិច្ចការនោះទេ ។ តែផ្ទុយទៅវិញការសង្គ្រោះនឹងមិនអាចកើតឡើងបានបើសិនជា បុរសយេស៊ូមិនបានរួមចំណែក ។ ដូចគ្នានឹងព្រះបន្ទូលជាលាយលក្ខណ៍អក្សរដែរ ព្រះបន្ទូលដែលចាប់កំណើតជាមនុស្ស ក៏ជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយ ។ ក្នុងនាមជាមនុស្ស ព្រះគ្រីស្តអាចមានបន្ទូលបានថា "ត្បិតខ្ញុំបានធ្វើជំរាប់ទុកឲ្យអ្នករាល់គ្នា ហើយដើម្បីឲ្យ

អ្នករាល់គ្នាត្រាប់តាមការដែលខ្ញុំបានធ្វើឲ្យនោះ" ។ សេចក្តីសង្គ្រោះដ៏អស់កល្ប គឺជាកិច្ចការរបស់ព្រះ ។ ប៉ុន្តែដោយព្រោះព្រះយេស៊ូ គឺជាព្រះអង្គសង្គ្រោះ វាក៏ជាកិច្ចការរបស់មនុស្សដែរ – ម្នាក់ដែលដូចយើងក្នុងគ្រប់ផ្លូវទាំងអស់ ។ សិរីល្អរបស់ព្រះនឹងមិនមានការថយចុះទេនៅពេលដែលទ្រង់ប្រើមនុស្ស – ហើយការស្តាប់បង្គាប់របស់ពួកគេ និងការលះបង់របស់ពួកគេ – ដើម្បីបំពេញគំរោងផែនការរបស់ព្រះអង្គ ។

## តើអ្នកណាសាងសង់ពួកជំនុំ?

For example, early in his ministry Jesus chose twelve men who would lead the church when he was gone. He called them "apostles"—a word signifying "those authorized to act in the sender's name." They were not volunteers but draftees, and Jesus was going to send them out to preach and cast out demons. So this was a responsible calling. But what was the first part of their job? Mark 3:14 reads, "He appointed twelve—naming them apostles—that they might be with him...." The first part of their call as leaders was simply to be with Jesus. They watched him, listened to him, observed his character, and learned his objectives and principles of ministry. Yes, they were going to lead, and in time they did. But their first task was to follow. Good Christian leaders were once good followers.

Joshua was a great leader. He commanded Israel in her campaign to conquer Canaan. But for long years before he served as leader he served as follower and aide to Moses.[1] Before becoming a great prophet Elisha "poured water on the hands of Elijah."[2] Timothy was fully aware of Paul's teaching and doctrine,[3] and had served the

[1]Ex 24:13; 33:11; Num 11:28; Jos 1:1.

[2]2 Ki 3:11.

[3]2 Tim 3:10-11.

great apostle as a son with his father.[4] That is why later he led so well.

Not only were biblical leaders good followers *before* they started to lead, they continued to be good followers *while* they led. Paul urged the Corinthians, "Follow my example, as I follow the example of Christ."[5] Paul was still following—day by day and hour by hour—the example of Christ. His following made him an effective leader. The minute we stop *following* Christ is the minute we stop effectively *leading*.

So good biblical leaders are good followers, as have been many secular business, political, and military chiefs.

How can we apply this principle? First, we ourselves should not rush into leadership. A wiser attitude is that of Solomon and Jeremiah.[6] Leadership is a great responsibility; those who point the way (and especially teach) will be judged more strictly.[7]

Second, we should therefore devote much energy to our own discipleship, preparation, and learning. Time spent in Bible study—both formal and personal—is an investment, not a luxury. "It is not good to have zeal without knowledge, nor to be hasty and miss the way."[8] Zeal without knowledge was Israel's problem; hence she missed her messiah.[9] True prophets excoriated their false counterparts who rushed to speak without stopping to hear Yahweh's council.[10] A hurried leader may plunge into battle only to discover that he has engaged the wrong enemy or is using inappropriate weapons and tactics. Further, a theological degree does not mean that its owner can relax and coast through serving and sermonizing. Following, learning, and growing are lifelong pursuits; it may thus be wise to choose a ministry where peers can continuously evaluate and correct us.

[4]Phil 2:22.

[5]1 Cor 11:1.

[6]1 Ki 3:7; Jer 1:6.

[7]Jas 3:1.

[8]Prov 19:2.

[9]Rom 10:2.

[10]e.g., Jer 23:16–32.

Third, we should not be too quick to promote others to leadership. Hence the warnings in the pastorals against new converts and hasty ordinations.[11] In our rapidly-growing Cambodian churches and NGOs we scrounge and pray for leaders, but before we appoint them let us be sure they are true followers of Jesus Christ and accomplished in whatever technical and people skills the position we envision requires. Ecclesiastical and organizational horror stories abound of aspiring young leaders who have assumed major responsibilities too quickly, only to succumb to pride, corruption, or temptation. "They must first be tested"[12] is a wise caution for all kinds of positions. It is not enough that a candidate be enthusiastic, personable, liked, and able to repeat catch phrases. We must also determine whether he or she is a skilled and proven follower.

## A Good Leader Serves

There has never been a stronger or more deserving leader than Jesus. He was always right. He is Immanuel—God with us—and hence savior and lord. He is worthy not only of obedience but also of worship, which we should render to no other. But *how* did Jesus lead? Did he parade his authority, forcing his subordinates to bow the knee and pamper him? Did he use his position to enrich himself? No. Jesus' leadership was characterized by service. In a key verse of Mark Jesus explained why he had come—"not ... to be served, but to serve, and to give his life as a ransom for many."[13] Jesus was and is the world's greatest and most deserving leader. But as leader he came to serve, and to serve in the most profound way—by giving his life. If we wish to follow his example, then we will lead by serving, not by exploiting our positions to make ourselves comfortable, powerful, or rich.

A leader who ignores this counsel may find himself without followers. That is what happened to Rehoboam. At the beginning of his reign Rehoboam's prospective subjects petitioned him for relief

---

[11] 1 Tim 3:6; 5:22.

[12] 1 Tim 3:10.

[13] Mk 10:45.

from the heavy tax burden his father had imposed. The elders counseled, "If today you will be a servant to these people and serve them and give them a favorable answer, they will always be your servants." But Rehoboam rejected that sage advice and heeded the young men who urged that he show the people who was boss. The result? He lost ten of the twelve tribes he should have ruled.[14] Heavy-handed leaders tend to lose their followers—certainly in their affections, often in their allegiance.

Paul, by contrast, led by serving, as did his Lord whom he followed. Instead of polishing his own reputation vis-à-vis Apollos he taught that both were merely servants, of no importance when compared with God, and not competing with but rather complementing one another.[15] As a servant he was willing to suffer for the church, which he often did.[16] In this way he became a great leader whom Christians still respect and follow today.

Similarly, if we today wish to be remembered as Pauls and not as Rehoboams, we must recall and practice Jesus' advice—"If anyone wants to be first, he must be the very last, and the servant of all."[17]

### A Good Leader Builds

Some leaders think that the best way they can use their position is to secure their own wealth, power, and reputation. Their job is certainly not to help others. They are interested in the welfare or advancement of constituents and subordinates only to the extent that these are encouraged to continue to support them. If another leader in the organization begins to rise in power or popularity, he or she is considered a threat that must be put down.

Leaders who think this way are consequently afraid of allowing those who work under them to succeed. They don't want associates to acquire skills they themselves lack, or to be seen too

---

[14]1 Ki 12:1–19.

[15]1 Cor 3:5–8.

[16]2 Cor 3:8–10; 6:3–10; Phil 2:17; Col 1:24–25; etc.

[17]Mark 9:35.

often in highly visible ministries. They fear that if others gain too many skills or too much recognition, their own status will be threatened. Nervous self-seekers then harass, publicly disgrace, demote, or fire rising stars. They may assign them to peripheral posts, or to jobs impossible to accomplish and certain to lead to criticism. Some sink to making scandalous innuendos or threats, or to inflicting physical harm.

By contrast, great leaders build their subordinates up and rejoice when they succeed.

Ephesians 4:11–16 tells why Christ gives spiritual gifts to individuals. It is not to make the recipients proud or powerful. No, spiritual gifts are given "to prepare God's people for works of service" (v. 12). My giftedness is not so that people will think I am great, but to equip me to help others so that they will be able to serve. A good leader does not try to do everything himself so that he keeps all the power and no one else develops ministry skills. Rather, a good leader works to build others up—to empower and enable them—and rejoices when *they* succeed. It is only when *everybody* in the church is working—not just the pastor—that "the body of Christ [is] built up" and "we all reach unity in the faith and in the knowledge of the Son of God and become mature" (v. 13).

So a good church leader continually asks himself, "Am I trying to do everything myself and to limit the opportunities of others so that all power remains with me? Or am I working to build others up so that *they also* may succeed?" Do we show others how to study the Bible for themselves? Do we show others how to care for the church's finances so that they are wisely spent and accounted for in an honest, open manner? Do we teach others how to teach and preach, and give them opportunities to do so? These are things that good leaders do—they *build others up* so that they can succeed.

Some leaders are afraid to do this because they fear that in time their disciples will do better than they themselves, and hence become more powerful and better known. It is true; that may happen. But that is O.K. The disciples of John the Baptist became jealous for John when Jesus started his ministry, because people were leaving John and following Jesus. But John replied, "He must become greater;

I must become less."[18] Andrew brought his brother Simon Peter to Jesus,[19] and soon Peter was better known than Andrew. When Saul of Tarsus came to faith, the early church thought his conversion was a ruse. But Barnabas believed Saul and introduced him to the church.[20] Before long Saul—the Apostle Paul—became stronger and better known than Barnabas. But if our love is for Jesus, and our deepest desire that he be honored and known, then it should be O.K. with us if God uses those we train even more than he uses us. After all, ministry is about the success of the church and the honor of Jesus' name, not our success and the honor of our name.

In the nineteenth century a nervous Sunday School teacher in the United States visited a shoe store to share the gospel with one of its salesmen. Most of us do not know the name of that Sunday School teacher, but many have heard of the shoe salesman. His name was Dwight L. Moody, and God used him as a great evangelist. Today a school, a radio ministry, and a publishing house bear his name. The follower surpassed the leader, but I'm sure that nervous Sunday School teacher thinks that is just fine.

We must conclude, therefore, that a good Christian leader is someone who does not focus on protecting or promoting himself. Rather he edifies others so that *they* can succeed.

### A Good Leader Leads

So far we have said that a leader is someone who follows, who serves, and who builds others. If that were all that the Bible says on this subject, we might conclude that a leader should never be strong or decisive. If a leader is a good follower, and one who serves and builds up others, then is it ever right that he should stand at the front and give bold, firm directions?

The answer to that question is an enthusiastic "Yes!" While it is true that a Christian leader, like Jesus, seeks to serve rather than be served, and, like Paul, to build up others' ministries rather than

---

[18]John 3:30.

[19]John 1:40–41.

[20]Acts 9:26–28.

focusing attention on himself, that does not mean that he does not act decisively. On the contrary, by definition a leader is someone who *leads!* He takes the initiative, points the way, and warns of dangers. He does not sit back and wait for others, or even for God, to do something. A good leader *serves* by *leading*.

Sometimes people bear the *title* of leader, but leave the actual *work* of leading to others. For example, Saul was Israel's first king. As king he was Israel's leader. So when the giant Goliath challenged Israel to battle, Saul should have been the one to accept that challenge. Rather than sitting in his tent with the title of leader, he should have stood up in God's strength and *led*. Instead it was the shepherd lad David who, although he had no *title*, stood strong in God's strength and *led* Israel that fateful day against her enemy. It was Saul's own fault that when the army returned from battle the women who came out to meet them celebrated David more than they did the king by singing, "Saul has slain his thousands, and David his ten thousands!"

This was not the first time that Saul, who bore the *title* of king and leader, failed to actually *lead*. In 1 Samuel 14:1 Saul's son Jonathan took the initiative to trust God and *lead* in an attack against Israel's enemies. Verse 2 shows us what the king was doing—sitting under a pomegranate tree with his six hundred men. Later in chapter 15 he let the people talk him into disobeying the LORD's command—he didn't take a stand and *lead* against their wishes. It is no wonder then that Saul's kingship did not last, and God found someone else who would lead his people as he should.

Leading means we will sometimes have to take a strong stand, and sometimes a lonely stand. Sometimes others may be afraid or asleep or ignorant, and be walking down the wrong path. That is when a leader stands tall and speaks strongly about what should be done, even if what he advocates is unpopular. He does this not to build his own status, but for the sake of the truth. Elijah was a strong leader who stood alone against Jezebel's four hundred prophets of Baal. He did this not for himself but for the sake of the truth. Jeremiah and other Old Testament prophets often took unpopular stands. Paul opposed Peter to his face in Galatians 2. He did this not to enhance his power or reputation at Peter's expense, but simply

because Peter was wrong. Peter needed to be corrected before he led a large segment of the church into error.

So even though a good leader first follows, and does not deprive others of training or opportunities in order to keep everybody's attention on himself, at times he serves them best by taking a strong stand to show them the way to go. A good leader *serves* by *leading*.

Because a leader has to actually *lead* his people, he must first be certain of the direction to take. That is why he must first have been a good follower. Leaders have to lead, but if they are unsure where they are going because they are not closely following the Lord, they may lead their flocks into disaster. That is what Jesus was talking about when he said of the Pharisees, "Leave them; they are blind guides. If a blind man leads a blind man, both will fall into a pit."[21] The Pharisees were not following the Lord. So although they were doing their job as leaders to lead, they did not know where they should be going and led their flocks into a pit. A good leader knows the way he should be going, and then boldly strikes out and leads his people down that path.

## A Good Leader Passes On the Baton

Footraces are popular athletic events. Runners crouch behind the starting line, and when the gun is fired all take off for the finish line. Many races are individual events. Each racer in an individual event is his own "team"—how she does and whether she wins depends solely upon herself. She has no teammates. But other races are relays. A relay team may consist of four members. As the race is ready to start, an official gives the first member of each team a small stick or baton to carry. When the gun is fired, this first member runs around the track carrying this baton. Then as each returns to the starting point the second member of his team is waiting. This second member starts to run alongside the first, and the first hands over the baton to him. The first member, having completed his lap, drops out and the second carries the baton and runs around the track. As he completes his circuit and approaches the starting line the third member

[21]Matt 15:14.

of the team is waiting. Again the baton must be handed off, and the second retires and the third takes over. This process continues until all team members have run with the baton around the course. The winner of the race is not any *individual*, but the *team* that runs together the best and can execute smooth and efficient handovers of the baton. If any individual team member does not work well with the others—racing alongside the one in front to take the baton from him, and making sure he firmly places the baton in the grasp of the one who follows him—his team will not win. Even if that individual runs the fastest lap of all the runners in that race, if he does not take and hand over the baton efficiently, his team will lose. A relay race is not about individual performance but about team performance.

Christian leadership is like that. We are not in leadership to draw attention to how well *we* lead, or evangelize, or teach, or preach. We are part of a team where we are called upon to do our part as best we can, and then hand on the baton to someone else.

Christian ministry started with Jesus. When the time came for him to finish his ministry by dying for us, being raised, and returning to heaven, he passed on the baton of ministry to his apostles. He told them, "Now I am going to him who sent me, . . . [and] you are filled with grief. But I tell you the truth: It is for your good that I am going away. Unless I go away, the Counselor will not come to you; but if I go, I will send him to you."[22] Later he said, "As the Father has sent me, I am sending you."[23] Jesus was leaving; he was handing over his ministry to them; and he would send the Holy Spirit to enable them to fulfill it.

So the apostles took over where Jesus personally had stopped. The New Testament talks about Jesus' apostles laying the foundation of the church.[24] But the apostles did not minister forever, though some of them did well and their ministries started the church. The time came when they had to hand over their work to others. Paul, for example, was personally commissioned by Christ, did his job well,

---

[22]John 16:5–7.

[23]John 20:21.

[24]1 Cor 3:10–12; Eph 2:2; Rev 21:14.

and then handed over his work to Timothy. Paul gave important instructions to his follower by commanding, "And the things you have heard me say in the presence of many witnesses entrust to reliable men who will also be qualified to teach others."[25] Timothy was to take the baton from Paul, run his own lap, and then pass the baton on "to reliable men" who would run their laps and then "be qualified to teach others." Christian ministry is not an individual race, designed to draw attention to individual stars or heros. It is a relay race where we take over message and commission first given to others, and after running our brief lap find someone to whom we can entrust the work.

As leaders, then, we should be always on the lookout for a few good people with whom we can invest extra energy so that some day they can take over smoothly and run well. Just as a relay race cannot be won if one team drops the baton or does not hand it over smoothly, so our Christian ministries will suffer if we do not have people trained and ready to take over when we move on.

Because Jesus knew he would soon be crucified and leave this earth, he spent much time in the latter part of his ministry training his disciples. After Peter came to the conclusion that Jesus was Israel's messiah, Jesus "began to explain to his disciples that he must go to Jerusalem and suffer. . . ."[26] It seems he spent more time with them and a smaller percentage with the crowds. Instead of doing all the preaching himself he sent out the Twelve, and later seventy others, to preach and teach. Rather than standing up himself and teaching, he gave others the opportunity to learn the skill, even though he could have done it better. He was preparing them to take the baton.

So if we are to be good leaders, not only must we do our own job well, we must constantly be training another to take our place. Are you doing this? Do you have someone with whom you meet for study and prayer? Do you take others with you as you minister, so that they can observe . . . and then share . . . and then take over?

---

[25]2 Tim 2:2.

[26]Matt 16:21.

សំណុំឆីកឃ្ញុំ ៤/១ (មករា ២០០៣): ១១៧-១៣៦



# លក្ខណៈសម្បត្តិរបស់អ្នកដឹកនាំ

*រ៉ាស់សែល បាវើស៍*

មេដឹកនាំខ្មែរក្រហមប៉ុលពត អ្នកម្តាយទេរីសារ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកប្រមុខរដ្ឋ ចេង ហេង ព្រះបរមគ្រូពុទ្ធនិយម គូតាម៉ាប៊ូដា មេភាវវករ អូសាម៉ា ប៊ីនឡាដិន ។ តើលក្ខណៈរួមដូចគ្នាអ្វីទៅដែលអស់លោកទាំងនោះមាន?

ពួកលោកជាអ្នកដឹកនាំ ។ ទោះជាល្អ ឬអាក្រក់ ដោយចេតនាថ្លៃថ្នូរ ឬមិនថ្លៃថ្នូរ គឺពួកលោកបានឈរនៅខាងមុខ ហើយបានប្រមូលផ្តុំជនរួមជាតិឲ្យដើរតាមខ្លួន ។ វាសនាមនុស្សរាប់លាននាក់មានលក្ខណៈបែបណានោះ គឺដោយសារតែអស់លោកប៉ុន្មាននាក់នេះឯង ។

អ្នកដឹកនាំដែលល្អ មិនអាចកំណត់តំលៃបានទេ ។ តើមនុស្សនឹងទៅជាយ៉ាងណាប្រសិនបើគេគ្មានការបំផុសគំនិត សេចក្តីក្លាហាន ការស្វែងយល់ និងប្រាជ្ញា? តើសេចក្តីសង្ឃឹមរបស់គេនឹងមិនរសាយបាត់ទៅហើយឬ? ផ្ទុយទៅវិញ អ្នកដឹកនាំអាក្រក់អាចបណ្តាលឲ្យមានទុក្ខសោកនិយាយមិនអស់ ឬធ្វើឲ្យមានសេចក្តីខ្មាសដល់អ្នកដើរតាម ។ បើ

សិនជាឲ្យឧទាហរណ៍វិញគឺមានច្រើនខ្លាំងណាស់ ហើយធ្វើឲ្យឈឺចាប់ក្នុងការនិទានចេញទៀតផង។

តើត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីឲ្យយើងរកឃើញថាអ្នកដឹកនាំមួយល្អ ហើយមួយទៀតមិនល្អបាន? តើយើងអាចក្លាយទៅជាអ្នកដឹកនាំល្អបានដោយរបៀបណា? ក្នុងប្រទេសកម្ពុជានៅពេលដែលក្រុមជំនុំកំពុងតែរីកចំរើនយ៉ាងលឿនបំផុតនោះ បន្ទុករបស់យើងគឺ ត្រូវហ្វឹកហ្វឺនអ្នកដឹកនាំជំនាន់ថ្មី។ តើទិសដៅរបស់យើងសំដៅទៅលើអ្វី? តើគុណភាពអ្វីទៅដែលយើងត្រូវស្វែងរកឲ្យឃើញ និងបង្កើតឲ្យមានឡើង?

អត្ថបទនេះមិនអាចឆ្លើយនូវសំនួរទាំងនេះឲ្យពេញលេញបានទេ ។ ប៉ុន្តែខ្ញុំសូមផ្ដល់នូវលក្ខណៈសម្បត្តិប្រាំយ៉ាងរបស់អ្នកចាប់ផ្ដើម ។ លក្ខណៈសម្បត្តិទាំងនេះ អាចប្រើជាប្រយោជន៍ដល់អ្នកដឹកនាំច្រើនប្រភេទ។ ប៉ុន្តែជាពិសេសនៅក្នុងក្រុមជំនុំ អ្នកដឹកនាំល្អគឺជាអ្នកដែលៈ

- ដើរតាម
- បំរើ
- កសាង
- នាំមុខ
- ហុចកំណាត់ឈើរត់ប្រណាំងបន្តទៅឲ្យអ្នកដទៃ

## អ្នកដឹកនាំល្អគឺជាអ្នកដើរតាម

វាហាក់បីដូចជាផ្ទុយគ្នាក្នុងការនិយាយថាអ្នកដឹកនាំជាអ្នកដើរតាមទៅវិញ ។ យើងតែងតែឮជារឿយៗមកថាអ្នកដឹកនាំគឺជាអ្នកឈរនៅខាងមុខបង្ហាញផ្លូវ និងចេញបញ្ជាផ្សេងៗ ប៉ុន្តែអ្នកដឹកនាំដែលល្អបំផុតគឺជា អ្នកចាប់ផ្ដើមចេញមកពីអ្នកដើរតាមយ៉ាងល្អជាមុនសិន ។ តើអ្នក

ដឹកនាំដឹងយ៉ាងណាបានអំពីរបៀបបណ្តាញនៃការងារ លុះត្រាតែគាត់មានបទពិសោធន៍នៅក្នុងឋានៈទាបនៃបណ្តាញការងារនោះជាមុនសិន ។

ដូច្នេះអ្នកដឹកនាំដែលប្រសើរបំផុត គឺចាប់ផ្តើមពីទាបមកមុន ។ ពួកលោកធ្លាប់រៀនស្តាប់បង្គាប់តាមការណែនាំ មុនដែលពួកលោកបានទទួលការប្រគល់ការទទួលខុសត្រូវឲ្យធ្វើ ។

ឧទាហរណ៍ កាលទើបតែចាប់ផ្តើមព័ន្ធកិច្ចដំបូង ព្រះយេស៊ូជ្រើសរើសមនុស្ស១២នាក់ ដែលនឹងដឹកនាំក្រុមជំនុំនៅពេលដែលទ្រង់ចាកចេញពីពួកគេ ។ ទ្រង់ហៅពួកគេថា "សាវ័ក" ដែលមានន័យថា "អ្នកដែលបានទទួលសិទ្ធអំណាច ឲ្យធ្វើសកម្មភាពអ្វីមួយបានក្នុងឈ្មោះអ្នកដែលបញ្ជូនមក" ។ ពួកគេមិនមែនស្ម័គ្រចិត្តទេ ប៉ុន្តែជាកូនកំណែនដែលព្រះអង្គបានជ្រើសរើស ហើយព្រះអង្គក៏បានបញ្ជូនពួកគេឲ្យចេញទៅប្រកាសដំណឹងល្អ និងដេញអារក្ស។ នេះហើយ គឺជាការទទួលខុសត្រូវចំពោះការត្រាស់ហៅ ។ ប៉ុន្តែផ្នែកដំបូងនៃកិច្ចការរបស់ពួកគេមានអ្វីខ្លះ? ម៉ាកុស ៣:១៤ បានចែងថា "ទ្រង់បានជ្រើសរើស១២នាក់ ឲ្យឈ្មោះពួកគេថាសាវ័ក ដើម្បីឲ្យពួកគេនៅជាមួយព្រះអង្គ..." ។ ដើម្បីឲ្យពួកគេទៅជាអ្នកដឹកនាំ ព្រះអង្គត្រាស់ហៅពួកគេឲ្យគ្រាន់តែនៅជាមួយព្រះអង្គសិន ។ ពួកគេមើលឃើញព្រះអង្គ ស្តាប់ព្រះអង្គ សង្កេតមើលលក្ខណៈសម្បត្តិរបស់ព្រះអង្គ ហើយរៀនពីគោលបំណងរបស់ព្រះអង្គ និងគោលការណ៍នៃព័ន្ធកិច្ច ។ ពិតប្រាកដពួកគេនឹងដឹកនាំ ហើយដល់ពេលកំណត់ ពួកគេក៏បានដឹកនាំមែន ។ ប៉ុន្តែភារកិច្ចដំបូងរបស់ពួកគេ គឺដើរតាម ។ អ្នកដឹកនាំគ្រីស្តបរិស័ទដែលល្អគឺជាអ្នកដែលធ្លាប់ដើរតាមបានយ៉ាងល្អ ។

យ៉ូស្វេគឺជាអ្នកដឹកនាំដ៏ល្អម្នាក់ ។ គាត់បានបញ្ជាពួកអ៊ីស្រាអែលនៅក្នុងសមរភូមិឲ្យយកឈ្នះលើទឹកដីកាណាន់ ។ ប៉ុន្តែជាច្រើនឆ្នាំមុនដែល គាត់បំរើជាអ្នកដឹកនាំ គាត់បានបំរើជាអ្នកដើរតាម និងជាអ្នកជំនួយ

ការដល់ម៉ូសេ[១] ។ អេលីសេមុនពេលដែលគាត់ក្លាយជាហោរាដ៏អស្ចារ្យម្នាក់ "គាត់បានចាក់ទឹកទៅលើដៃរបស់អេលីយ៉ា"[២] ។ ធីម៉ូថេបានដឹងយ៉ាងច្បាស់ពីសេចក្តីបង្រៀន និងគោលលទ្ធិរបស់ប៉ុល[៣] ហើយបានបំរើសាវ័កដ៏អស្ចារ្យទុកជាកូន និងឪពុក[៤] ។ ដូច្នេះហើយបានជាបន្ទាប់មកគាត់ដឹកនាំបានយ៉ាងល្អ ។

អ្នកដឹកនាំតាមបែបព្រះគម្ពីរមិនមែនគ្រាន់តែជាអ្នកដើរតាមល្អមុនពេលចាប់ផ្តើមដឹកនាំប៉ុណ្ណោះទេ គឺពួកគេនៅតែបន្តជាអ្នកដើរតាមល្អជានិច្ច ក្នុងខណៈពេលដែលគេកំពុងតែធ្វើជាអ្នកដឹកនាំផងដែរ ។ លោកប៉ុល បានជំរុញទឹកចិត្តពួកកូរិនថូសថា "ចូរធ្វើតាមគំរូខ្ញុំ ដូចជាខ្ញុំធ្វើតាមគំរូនៃព្រះគ្រីស្ទដែរ"[៥] ។ លោកប៉ុល នៅតែដើរតាមគំរូព្រះគ្រីស្ទជានិច្ចជារៀងរាល់ថ្ងៃ និងជារៀងរាល់ម៉ោង ។ ការដែលគាត់ដាក់ចិត្តធ្វើជាអ្នកដើរតាមគំរូព្រះគ្រីស្ទធ្វើឲ្យគាត់ក្លាយទៅជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាព ។ នាទីណាដែលយើងឈប់ដើរតាមព្រះគ្រីស្ទ នាទីនោះគឺជាទីបញ្ចប់នៃការក្លាយជាអ្នកដឹកនាំល្អហើយ ។

ដូច្នេះអ្នកដឹកនាំល្អតាមបែបព្រះគម្ពីរ គឺជាអ្នកដើតាមដ៏ល្អដែរដូចគ្នានឹងថៅកែជំនួញ អ្នកដឹកនាំនយោបាយ និងមេដឹកនាំលោកីយ៍ផ្សេងៗជាច្រើន ដែលយើងបានឆ្លងកាត់រួចមកហើយ ។

តើយើងអនុវត្តគោលការណ៍នេះយ៉ាងដូចម្តេចបាន?

---

[1] *និក្ខមនំ ២៤:១៣; ៣៣:១១; ជនគណនា ១១:២៨; យ៉ូស្វេ ១:១*

[2] *ពង្សាវតាក្សត្រ ៣:១១*

[3] *២ធីម៉ូថេ ៣:១០-១១*

[4] *ភីលីព ២:២២*

[5] *១កូរិនថូស ១១:១*

ទីមួយ: ខ្លួនយើងផ្ទាល់ មិនត្រូវប្រញាប់ចូលទៅក្នុងថ្នាក់ដឹកនាំភ្លាមៗនោះឡើយ ។ អត្តចរិតប្រកបដោយប្រាជ្ញា គឺជាអត្តចរិតដូចជាសាឡូម៉ូន និងយេរេមា[6] ។ ការដឹកនាំគឺជាការទទួលខុសត្រូវដ៏ធំធេងមួយ អ្នកចង្អុលផ្លូវ (ជាពិសេសអ្នកបង្រៀន) ព្រោះអ្នកបង្រៀនគេនឹងត្រូវទទួលទោសខ្លាំងជាងគេ[7] ។

ទីពីរ: យើងត្រូវតែ ចំណាយកំលាំងយើងយ៉ាងខ្លាំងទៅក្នុងការបង្កើតសិស្ស ការរៀបចំ និងការរៀនសូត្រទៅលើខ្លួនយើង ។ ការចំណាយពេលសិក្សាព្រះគម្ពីររួមគ្នា និងផ្ទាល់ខ្លួន គឺជាការបណ្តាក់ទុនមួយយ៉ាងសំខាន់ មិនមែនជាភាពស្រណុកស្រួលនោះទេ ។ "ភាពឆេះឆួល ដោយគ្មានតំរិះ មិនមែនជាការល្អឡើយ រីឯការខំទាំងញាក់ញ័រក៏ដូចតែគ្នា"[8] ។ ភាពឆេះឆួលដោយគ្មានតំរិះ គឺជាបញ្ហារបស់អ៊ីស្រាអែល ។ ហេតុដូច្នេះហើយបានជាពួកគេមិនស្គាល់ព្រះមែស៊ីរបស់ខ្លួន[9] ។ ហោរាពិតប្រាកដស្តីបន្ទោសដល់ហោរាក្លែងក្លាយ ដោយព្រោះតែពួកគេប្រញាប់ក្នុងការនិយាយ ដោយមិនបានស្តាប់ការប្រឹក្សាមកពីព្រះយេហូវ៉ាជាមុន[10] ។ អ្នកដឹកនាំដែលញាក់ញ័ររហ័សពេក អាចបោះពួយយ៉ាងខ្លាំងចូលទៅក្នុងសង្គ្រាម រួចហើយទើបដឹងថា គេជួបនឹងសត្រូវ ហើយក៏ចាប់ផ្តើមប្រើអាវុធ និងយុទ្ធសាស្ត្រ ដោយមិនសមទៅតាមកាលៈទេសៈ ។ ជាងនេះទៅទៀត សញ្ញាប័ត្រទេវវិទ្យាមិនមែនមានន័យថា ម្ចាស់សញ្ញាប័ត្រនោះអាចសំរាក និងបណ្តែតបណ្តោយតាមរយៈការបំរើ និងការរៀបចំ

---

[6] *១ពង្សាវតាក្សត្រ ៣:៧; យេរេមា ១:៦*

[7] *យ៉ាកុប ៣:១*

[8] *សុភាសិត ១៩:២*

[9] *រ៉ូម ១០:២*

[10] *ឧទាហរណ៍; យេរេមា ២៣:១៦:៣២*

សេចក្តីអធិប្បាយប៉ុណ្ណោះនោះទេ ។ ការធ្វើតាម ការរៀនសូត្រ និង ភាពលូតលាស់ គឺជាការខិតខំប្រឹងប្រែងមួយជីវិត ។ ជាការឈ្លាសវៃ កាលណាយើងជ្រើសរើសព័ន្ធកិច្ចគ្រីស្ទជួយវាយតំលៃ និងការកែតំរង់ ។

ទីបី: យើងមិនត្រូវជ្រើសរើសអ្នកណាចូលទៅក្នុងថ្នាក់ដឹកនាំលឿនពេកទេ ។ ដូច្នេះហើយការដាស់តឿននៅក្នុងការដឹកនាំជាគ្រូគង្វាល គឺប្រឆាំងទៅនឹងអ្នកទើបតែជឿថ្មី និងភាពប្រញាប់ប្រញាល់នៃការចាត់ប្រេងតាំងឲ្យ[11] ។ នៅក្នុងការរីកចំរើនយ៉ាងឆាប់រហ័សរបស់យើង ក្រុមជំនុំ និង អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ត្រូវតែទូលអង្វរ និងអធិស្ឋានសំរាប់អ្នកដឹកនាំជាមុន មុននឹងយើងតែងតាំងពួកគេឡើងឲ្យដឹកនាំ ដើម្បីឲ្យយើងដឹងពិតប្រាកដថា ពួកគេពិតជាអ្នកដើរតាមព្រះយេស៊ូដ៏ពិតប្រាកដមែន និងមានគ្រប់ទាំងបច្ចេកទេស និងជំនាញនៅក្នុងឋានៈ ដែលតំរូវឲ្យពួកគេធ្វើ។ រឿងដែលគួរឲ្យសោកស្តាយរបស់ក្រុមជំនុំ និងអង្គការផ្សេងៗ នោះគឺកើតមានឡើងចំពោះអ្នកដឹកនាំក្មេងខ្ចី ដែលបានទទួលនូវការទទួលខុសត្រូវក្នុងផ្នែកសំខាន់ៗឆាប់រហ័សពេក ធ្វើឲ្យពួកគេសម្បូរណ៍ទៅដោយមហិច្ឆិតា ដែលនាំឲ្យគេបង្អោនទៅរកភាពអំនួត ពុករលួយ ឬសេចក្តីល្បួង ។ "ពួកគេត្រូវតែទទួលការសាកល្បងជាមុនសិន"[12] ព្រោះវាជាការប្រុងប្រយ័ត្នដ៏ឈ្លាសវៃ សំរាប់គ្រប់ទាំងប្រភេទនៃឋានៈណាក៏ដោយ ។ វាមិនគ្រប់គ្រាន់ទេ ប្រសិនបើបេក្ខជនគ្រាន់តែមានចិត្តឆេះ ឆួល លក្ខណៈសម្បត្តិសមរម្យ ចូលចិត្ត ហើយមានសមត្ថភាពទន្ទេញតាមចាំនោះ ។ យើងត្រូវស្វែងយល់ឲ្យដឹងថា តើគាត់មានអ្នកដើរតាមមែនដែរ ឬទេ ។

---

[11] ១ធីម៉ូថេ ៣:៦; ៥:២២

[12] ១ធីម៉ូថេ ៣:១០

## អ្នកដឹកនាំល្អគឺជាអ្នកបំរើ

មិនដែលមានអ្នកដឹកនាំណាមួយខ្លាំងក្លា ឬគួរឲ្យសរសើរ លើសព្រះយេស៊ូឡើយ ។ ទ្រង់តែងតែត្រឹមត្រូវជានិច្ច ។ ទ្រង់ គឺជាអ៊ីម៉ាញូអែល "ព្រះគង់ជាមួយយើង" ហើយជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ ។ ទ្រង់មិនមែនគ្រាន់តែជាព្រះដែលគួរឲ្យយើងស្តាប់បង្គាប់ តែប៉ុណ្ណោះទេ ប៉ុន្តែទ្រង់គួរឲ្យយើងថ្វាយបង្គំទៀតផង យើងមិនគួរទៅថ្វាយបង្គំព្រះឯណាផ្សេងទៀតក្រៅពីព្រះអង្គឡើយ ។ បើសិនជាដូច្នេះមែនតើព្រះយេស៊ូដឹកនាំដោយរបៀណា? តើទ្រង់សំដែងអំណាចរបស់ទ្រង់ ដោយបង្ខំអ្នកដែលនៅក្រោមព្រះអង្គ ឲ្យក្រាបដោយលុតជង្គង់ ហើយញាប់ញ័រនៅចំពោះទ្រង់ឬ? តើទ្រង់ប្រើឋានៈរបស់ព្រះអង្គដើម្បី លើកអង្គទ្រង់ឡើងមែនទេ? មិនមែនដូច្នេះឡើយ ។ ការដឹកនាំរបស់ព្រះយេស៊ូ បានបង្ហាញតាមរយៈការបំរើ ។ នៅក្នុងខគម្ពីររបស់ម៉ាកុស ព្រះយេស៊ូបានពន្យល់ហេតុអ្វីបានជាទ្រង់ត្រូវមក "មិនមែន... ដើម្បីឲ្យគេបំរើ ប៉ុន្តែដើម្បីបំរើគេវិញ ហើយនឹងលះបង់ជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង"[១៣] ។ ព្រះយេស៊ូជាអ្នកដឹកនាំដ៏អស្ចារ្យ និងគួរសរសើរបំផុត តាំងតែពីមុនរហូតដល់សព្វថ្ងៃនេះ ។ ប៉ុន្តែក្នុងនាមជាអ្នកដឹកនាំ ទ្រង់យាងមកដើម្បីបំរើ ហើយបំរើនៅក្នុងផ្លូវដ៏អស្ចារ្យបំផុត ដោយការប្រគល់នូវជីវិតរបស់ព្រះអង្គ ។ ប្រសិនបើយើងប្រាថ្នាចង់ធ្វើតាមគំរូរបស់ព្រះអង្គនោះ យើងត្រូវដឹកនាំដោយការបំរើ មិនមែនប្រើឋានៈរបស់យើង ដើម្បីក្រេបជញ្ជក់យកផលប្រយោជន៍ពីអ្នកដទៃឡើយ ដើម្បីឲ្យមានភាពសុខស្រួល អំណាច ឬក្លាយជាអ្នកមានដល់ខ្លួនឯងតែប៉ុណ្ណោះនោះឡើយ ។

---

[13] *ម៉ាកុស ១០:៤៥*

អ្នកដឹកនាំណាដែលបដិសេធការប្រឹក្សានេះ នោះប្រហែលជារកឃើញថា ខ្លួនគេគ្មានអ្នកដើរតាមឡើយ ។ នេះឯងជាការដែលកើតឡើងដល់រេហូបោម ។ នៅឯការចាប់ផ្ដើមគ្រងរាជ្យដំបូង អ្នកដែលសង្ឃឹមពីរេហូបោម គឺចង់ឲ្យទ្រង់សម្រាលពន្ធដ៏ធ្ងន់ធ្ងរដែលបិតារបស់ទ្រង់បានដាក់ដល់ប្រជារាស្ត្រ ។ ពួកចាស់ទុំបានជួយប្រឹក្សាទ្រង់ថា "នៅថ្ងៃនេះ បើទ្រង់សព្វព្រះទ័យ និងធ្វើតាមចិត្តប្រជាជនទាំងឡាយ ហើយយកចិត្តគេដោយឆ្លើយនឹងគេ ជាពាក្យផ្អែមពិរោះ នោះគេនឹងនៅជាបាវបំរើទ្រង់ជាដរាបទៅ" ។ ប៉ុន្តែរេហូបោមបដិសេធគំនិតនៃពួកចាស់ទុំទាំងនោះ ហើយបែរទៅប្រឹក្សាជាមួយមនុស្សស្រករនឹងទ្រង់វិញ ដែលឲ្យគំនិតថា ទ្រង់គួរបង្ហាញឲ្យពួកគេដឹងថាទ្រង់ជាចៅហ្វាយពួកគេ ។ លទ្ធផល គឺទ្រង់បាត់បង់ពូជអំបូរទាំង១២ ដែលទ្រង់ត្រូវគ្រប់គ្រងលើពួកគេ[១៤] ។ អ្នកដឹកនាំក្បាលរឹងតែងតែបាត់បង់អ្នកដើរតាមខ្លួន ។ ពិតប្រាកដហើយនៅក្នុងការថ្នាក់ថ្នមរបស់ពួកគេ គឺតែងតែមានភក្ដីភាពនៅក្នុងពួកគេ ។

ផ្ទុយទៅវិញលោកប៉ុល ដឹកនាំក្នុងភាពជាអ្នកបំរើ ដូចដែលព្រះអម្ចាស់របស់គាត់បានធ្វើ និងជាអ្នកដែលគាត់បានដើរតាម ។ ជំនួសឲ្យការដុសខាត់កេរ្តិ៍ឈ្មោះរបស់ខ្លួនឲ្យកាន់តែភ្លឺឡើង បើប្រៀបធៀបទៅនឹងអាប៉ូឡូស គាត់បានបង្រៀនថាយើងទាំងពីរគ្រាន់តែជាអ្នកបំរើគ្មានសារៈប្រយោជន៍អ្វីទេ ប្រសិនបើប្រៀបធៀបទៅនឹងព្រះជាម្ចាស់ ហើយក៏មិនមែនប្រលងប្រណាំងជាមួយគ្នាឡើយ ប៉ុន្តែពឹងពាក់គ្នា ទៅវិញទៅមក[១៥] ។ ក្នុងនាមជាអ្នកបំរើ គាត់យល់ព្រមរងទុក្ខសំរាប់ក្រុមជំនុំ ហើយគាត់តែងតែធ្វើជានិច្ច[១៦] ។ ដោយព្រោះតែគាត់ធ្វើយ៉ាងដូច្នេះ បានជាគាត់

---

[14] *១ពង្សាវតាក្សត្រ ១២:១-១៩*

[15] *១កូរិនថូស ៣:៥-៨*

[16] *២កូរិនថូស ៣:៨-១០; ភីលីព ២:១៧; កូលុស ១:២៤-២៥ ។ល។*

ក្លាយទៅជា អ្នកដឹកនាំដ៏អស្ចារ្យម្នាក់ ដែលគ្រីស្ទបរិស័ទ នៅតែគោរព និងដើរតាមរហូតដល់សព្វថ្ងៃនេះ ។

ស្រដៀងគ្នាផងដែរ ប្រសិនបើយើងសព្វថ្ងៃនេះ ប្រាថ្នាចង់ឲ្យគេចងចាំដូចលោកប៉ុល មិនមែនដូច អេហ្វបោម យើងត្រូវតែរំលឹកឡើងវិញ និងអនុវត្តនូវដំបូន្មានរបស់ព្រះយេស៊ូ "បើអ្នកណាចង់ធ្វើជាលេខ១ នោះត្រូវទៅជាចុងបង្អស់វិញ ហើយត្រូវបំរើគេទាំងអស់ដែរ"[១៧] ។

## អ្នកដឹកនាំល្អគឺជាអ្នកកសាង

អ្នកដឹកនាំខ្លះគិត ថាមធ្យោបាយដែលប្រសើរក្នុងការដែលគេប្រើឋានៈរបស់ខ្លួនបាន គឺជាការដែលគេរក្សាទ្រព្យសម្បត្តិ អំណាច និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឲ្យមានសុវត្ថិភាព ។ កិច្ចការពិតប្រាកដរបស់គេគឺមិនជាការជួយអ្នកដទៃទេឡើយ ។ ពួកគេចាប់អារម្មណ៍តែទៅលើសុខមាលភាព ឬភាពរីកចំរើននៃសមាជិក និងអ្នកនៅពីក្រោមគេ ក្នុងករណីណាដែលការទាំងអស់នោះជួយលើកទឹកចិត្ត និងផ្គត់ផ្គង់ពួកគេតែប៉ុណ្ណោះ ។ ប្រសិនបើអ្នកដឹកនាំដទៃទៀតនៅក្នុងអង្គភាព ចាប់ផ្តើមងើបឡើងនៅក្នុងអំណាច ឬភាពល្បីល្បាញ គឺគាត់បានពិចារណាថា ជាសញ្ញាដែលគាត់ត្រូវទំលាក់ពួកនោះចុះវិញហើយ ។

អ្នកដឹកនាំណាដែលគិតតែនៅក្នុងផ្លូវនេះ លទ្ធផលរបស់ពួកគេគឺមានតែការភ័យខ្លាច ចំពោះអ្នកដែលធ្វើការនៅក្រោមខ្លួន បានទទួលជោគជ័យ ។ ពួកគេមិនចង់រួមចំណែក ដើម្បីទទួលនូវជំនាញថ្មីទៀតដែលពួកគេខ្វះខាតនោះទេ ឬតែងតែមានបំណងចង់ឲ្យគេឃើញខ្លួនជាចំហថាខ្លួនឯងខ្ពង់ខ្ពស់នៅក្នុងការបំរើព្រះ ។ ពួកគេគិតថា ប្រសិនបើមាន

---

[17] ម៉ាកុស ៩:៣៥

អ្នកដទៃណាបានទទួលជំនាញយ៉ាងច្រើន ឬមានការទទួលស្គាល់យ៉ាងច្រើននោះ ឋានៈរបស់គេនឹងត្រូវបានគេដណ្ដើមយកពីខ្លួន ។ ការភ័យខ្លាចចំពោះអ្នកដែលគិតតែពីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួននោះ បណ្ដាលឲ្យមានភាពរំខាន មានការអាប់កេរ្តិ៍ឈ្មោះជាសាធារណៈ និងបង្ហាញ ឬធ្វើឲ្យមានផ្កាភ្លើងកើតឡើង ។ ប្រហែលជាគេបញ្ជូនឲ្យទៅបរិមណ្ឌល ឬការងារណាមួយ ដើម្បីឲ្យទទួលបរាជ័យនោះពិតប្រាកដណាស់ពួកគេនឹងរិះគន់ ។ ភាពស្រុតចុះខ្លះបណ្ដាលឲ្យមានការកើតរឿងអាស្រូវ ការគំរាមកំហែង ឬធ្វើឲ្យមានការឈឺចាប់ខាងឯផ្លូវកាយ ។

ផ្ទុយទៅវិញ អ្នកដឹកនាំដែលល្អកសាងអ្នកដែលនៅក្រោមខ្លួនឡើង ហើយមានអំណរនៅពេលដែលពួកគេទទួលបានជោគជ័យ ។

អេភេសូរ ៤:១១-១៦ ប្រាប់អំពីមូលហេតុអ្វីដែលព្រះគ្រីស្ទផ្ដល់អំណោយទានខាងវិញ្ញាណដល់មនុស្សម្នាក់ៗ គឺមិនមែនដើម្បីឲ្យពួកគេមានភាពអំនួត និងអំណាចនោះទេ។ អំណោយទានដែលទ្រង់ប្រទានមកគឺ "ដើម្បីរៀបចំរាស្ត្ររបស់ព្រះសំរាប់ធ្វើការជំនួយ" (ខ.១២) ។ អំណោយទានដែល ខ្ញុំមានមិនមែនដើម្បីឲ្យមនុស្សគិតថាខ្ញុំអស្ចារ្យនោះទេ ប៉ុន្តែបំពាក់បំប៉នខ្ញុំដើម្បីជួយអ្នកឯទៀត ដើម្បីឲ្យគេអាចធ្វើការជំនួយដូចជាខ្ញុំបានដែរ ។ អ្នកដឹកនាំដែលល្អមិនមែនព្យាយាមធ្វើការទាំងអស់តែម្នាក់ឯង ដើម្បីរក្សាអំណាចទាំងអស់សំរាប់តែខ្លួនឯង ហើយគ្មានការអភិវឌ្ឍន៍ជំនាញអ្វីដល់អ្នកណាម្នាក់នោះទេ ។ ប៉ុន្តែអ្នកដឹកនាំដែលល្អពិតនោះគឺធ្វើការសង់អ្នកដទៃឡើង ផ្ដល់អំណាចដល់គេ និងជួយពួកគេ ហើយមានភាពអំណរនៅពេលដែលពួកគេបានទទួលជ័យជំនះ ។ ទាល់តែយើងគ្រប់គ្នានៅក្នុងក្រុមជំនុំធ្វើការទាំងអស់គ្នា មិនមែនធ្វើការតែគ្រូគង្វាលម្នាក់ឯងនោះទេ នោះទើប "រូបកាយរបស់ព្រះគ្រីស្ទ ត្រូវបានសង់ឡើង" ហើយ "យើងរាល់គ្នាបានរួបរួម ខាងឯសេចក្ដីជំនឿរួចជា

ស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់ គឺដល់បាន ពេញជាមនុស្ស " (ខ. ១៣) ។

ដូច្នេះក្នុងនាមជាអ្នកដឹកនាំក្រុមជំនុំល្អ សូមបន្តសួរខ្លួនឯងថា "តើអញកំពុងព្យាយាមធ្វើការទាំងអស់តែម្នាក់ឯង ហើយបិទឱកាសមិនឲ្យអ្នកដទៃធ្វើការ ដើម្បីឲ្យអំណាចទាំងអស់មានតែនៅខ្លួនអញម្នាក់ឯងឬ?" ឬអញកំពុងកសាងអ្នកដទៃឡើង ដើម្បីឲ្យពួកគេជំនួសកន្លែងអញបាន ។ តើយើងបានបង្រៀនអ្នកឯទៀតឲ្យចេះសិក្សាព្រះគម្ពីរដោយខ្លួនឯង ហើយឬនៅ? តើយើងបង្ហាញអ្នកឯទៀតឲ្យចេះកាន់លុយឲ្យបានត្រឹមត្រូវហើយឬនៅ ដើម្បីឲ្យពួកគេចេះចំណាយដោយឈ្លាសវៃ ហើយទុកដាក់ដោយស្មោះត្រង់ចំពោះសាធារណៈ? តើយើងមានបង្រៀនអ្នកឯទៀតឲ្យ ចេះបង្រៀន និងចេះអធិប្បាយហើយឬទេ ព្រមទាំងផ្ដល់ឱកាសឲ្យពួកគេអនុវត្តដែរឬទេ? ទាំងនេះគឺជាកិច្ចការដែលអ្នកដឹកនាំល្អត្រូវធ្វើ ពួកគេត្រូវតែកសាងអ្នកដទៃឡើង ដើម្បីឲ្យពួកគេទទួលតំណែងបន្ត ។

អ្នកដឹកនាំខ្លះ ខ្លាចក្នុងការធ្វើដូច្នេះ ពីព្រោះគេខ្លាចថា នៅពេលមួយដែលសិស្សរបស់គេធ្វើការបានល្អប្រសើរជាងខ្លួន នោះពួកគេនឹងមានអំណាច ហើយមានការទទួលស្គាល់ខ្លាំងជាង ។ វាជាការពិត ហើយអាចកើតឡើងបានមែន ។ ប៉ុន្តែវាមិនអីទេ ។ សិស្សរបស់លោកយ៉ូហានបាបទីស្ទ មានការច្រណែនជំនួសលោក នៅពេលដែលពួកគេឃើញ ព្រះយេស៊ូបានចាប់ផ្ដើមព័ន្ធកិច្ចរបស់ព្រះអង្គ ពីព្រោះមានមនុស្សជាច្រើនចាប់ផ្ដើមចាកចេញពីលោក យ៉ូហាន ទៅតាមព្រះយេស៊ូ ។ ប៉ុន្តែលោក យ៉ូហាន និយាយថា "ត្រូវឲ្យព្រះអង្គនោះបានចំរើនឡើង ហើយខ្ញុំត្រូវថយវិញ"[១៨]។ លោកអនទ្រេបាននាំបងរបស់គាត់គឺលោក ស៊ីម៉ូន ពេត្រុស ទៅចំពោះ

---

[18] *យ៉ូហាន ៣:៣០*

ព្រះយេស៊ូ[19] ហើយក្រោយមកលោកពេត្រុសមានភាពល្បីល្បាញជាង លោក អនទ្រេ ។ នៅពេលដែលលោក សុល នៃតាសុស បានមកដល់ សេចក្តីជំនឿ ក្រុមជំនុំដំបូងគិតថា ការប្រែចិត្តរបស់គាត់ គឺជាល្បិចកល ។ ប៉ុន្តែបាណាបាសបានជឿទៅលើសុល ព្រមទាំងណែនាំគាត់ទៅដល់ ក្រុមជំនុំទៀតផង[20] ។ មិនយូរប៉ុន្មាន សុល ដែលជា សាវ័ក ប៉ុល បានក្លាយ ទៅជាអ្នកដ៏ខ្លាំងក្លាម្នាក់ និងមានឈ្មោះល្បីជាង បាណាបាស ។ ប៉ុន្តែ ប្រសិនបើយើងមានសេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូ ហើយមានឆន្ទៈ ដ៏ជ្រាលជ្រៅ ដើម្បីឲ្យព្រះនាមព្រះបានថ្កើងឡើង និងឲ្យគេទទួលស្គាល់ នោះ ពិតជាមិនអីទេចំពោះយើង ប្រសិនបើទ្រង់ប្រើអ្នកដែលយើង ហ្វឹកហ្វឺនច្រើនជាងខ្លួនយើងក៏ដោយ ។ ព្រោះព័ន្ធកិច្ចទាំងអស់ គឺជា ជ័យជំនះរបស់ក្រុមជំនុំ និងថ្វាយព្រះកិត្តិនាមដល់ព្រះយេស៊ូ មិនមែនជា ជ័យជំនះរបស់យើង ឬផ្តល់កិត្តិនាមដល់ខ្លួនយើងនោះទេ ។

នៅក្នុងសតវត្សទី ១៩ គ្រូសាលារៀនថ្ងៃអាទិត្យដ៏ភ័យខ្លាចមួយ នៅក្នុងសហរដ្ឋអាមេរិក បានទៅតូបលក់ស្បែកជើងដើម្បីចែកចាយ ដំណឹងល្អដល់អ្នកលក់ស្បែកជើងម្នាក់ ។ យើងភាគច្រើនមិនបានស្គាល់ ឈ្មោះគ្រូសាលារៀនថ្ងៃអាទិត្យនោះទេ ប៉ុន្តែយើងភាគច្រើនធ្លាប់ឮអំពីអ្នក លក់ស្បែកជើង។ ឈ្មោះរបស់គាត់គឺ ដ្វៃ ម៉ូឌី (Dwight L. Moody) ព្រះបានប្រើគាត់ជាអ្នកផ្សាយដំណឹងល្អដ៏អស្ចារ្យម្នាក់ ។ សព្វថ្ងៃនេះ សាលារៀន ព័ន្ធកិច្ចវិទ្យុ និងរោងពុម្ព បានដាក់ឈ្មោះគាត់ ។ អ្នកដើរ តាមបានរីកលូតលាស់ជាងអ្នកដឹកនាំ ប៉ុន្តែខ្ញុំដឹងពិតប្រាកដថា គ្រូសាលា រៀនថ្ងៃអាទិត្យដ៏ភ័យខ្លាចម្នាក់នោះគិតថា វាជាការប្រពៃណាស់ ។

---

[19] *យ៉ូហាន ១:៤០-៤១*

[20] *កិច្ចការ ៩:២៦-២៨*

ដូច្នេះយើងសរុបមកវិញថា អ្នកដឹកនាំគ្រីស្ទបរិស័ទដែលល្អ គឺជាអ្នកដែលមិនផ្តោតទៅលើសុវត្ថិភាព និងការតំកើងខ្លួនឯង ។ ប៉ុន្តែគាត់បង្រៀនអ្នកដទៃទៀត ដើម្បីឲ្យពួកគេអាចទទួលកន្លែងបន្តពីគាត់ ។

## អ្នកដឹកនាំល្អគឺជាអ្នកនាំមុខ

យើងបាននិយាយជាច្រើនមកហើយអំពីអ្នកដឹកនាំជាអ្នកដើរតាមជាអ្នកបំរើ និងជាអ្នកកសាងអ្នកដទៃឡើង ។ ប្រសិនបើទាំងអស់នេះគ្រប់គ្រាន់ហើយចំពោះអ្វី ដែលព្រះគម្ពីរបានបង្រៀនទៅលើប្រធានបទនេះ នោះយើងអាចសរុបបានថា អ្នកដឹកនាំនឹងមិនដែលក្លាយទៅជាអ្នករឹងមាំ ឬជាអ្នកមិនរុញរានោះបានឡើយ ។ ប្រសិនបើអ្នកដឹកនាំជាអ្នកដើរតាមល្អ ជាអ្នកបំរើ ហើយជាអ្នកកសាងអ្នកដទៃឡើងមែន នោះតើវាត្រឹមត្រូវទេដែលថា គាត់ត្រូវតែឈរនៅខាងមុខ ហើយបង្ហាញនូវសេចក្តីក្លាហានព្រមទាំងផ្តល់នូវការណែនាំដ៏មុឹងម៉ាត់នោះ?

ចំលើយទៅចំពោះសំណួរនេះ គឺពិតជា "ត្រឹមត្រូវណាស់" ។ ក្នុងខណៈពេលដែលវាជាការពិត អ្នកដឹកនាំគ្រីស្ទបរិស័ទ ដូចជាព្រះយេស៊ូជាដើម ព្រះអង្គស្វះស្វែងក្នុងការបំរើជាជាងឲ្យគេមកបំរើព្រះអង្គ និងដូចជាលោក ប៉ុល កសាងព័ន្ធកិច្ចរបស់អ្នកដទៃឡើង ជាជាងផ្តោតការចាប់អារម្មណ៍តែទៅលើខ្លួនឯង កន្លែងនេះមិនមែនមានន័យថា គាត់ជាអ្នករុញរានោះទេ ។ តែផ្ទុយទៅវិញ អ្នកដឹកនាំគឺជាអ្នកដែលនាំមុខគេ ។ គាត់ធ្វើការចាប់ផ្តើមចង្អុលផ្លូវ ហើយដាស់តឿនមុនមានគ្រោះថ្នាក់ ។ គាត់មិនត្រូវអង្គុយ ហើយរង់ចាំអ្នកដទៃ ឬរង់ចាំព្រះ ឲ្យធ្វើការអ្វីមួយឡើយ ។ អ្នកដឹកនាំល្អបំរើដោយនាំមុខគេ ។

ពេលខ្លះមនុស្សទទួលនាមជាអ្នកដឹកនាំ ប៉ុន្តែចាកចោលការងារពិតនៃការនាំមុខអ្នកដទៃ ។ ឧទាហរណ៍ ស្តេចសូល គឺជាស្តេចទីមួយ

នៃអ៊ីស្រាអែល ។ ក្នុងឋានៈជាស្តេច ទ្រង់គឺជាអ្នកដឹកនាំអ៊ីស្រាអែល ។ ដូច្នេះ នៅពេលដែលយ័ក្ស កុលលីយ៉ាត បបួលអ៊ីស្រាអែលធ្វើសង្គ្រាម ស្តេចសូលត្រូវតែជាអ្នកដែលទទួលនូវការបបួលនេះ ។ ប៉ុន្តែទ្រង់បែរជាអង្គុយនៅក្នុងត្រសាលរបស់ទ្រង់ ក្រោមការបំពាក់នាមជាអ្នកដឹកនាំទៅវិញ ។ តាមពិត ទ្រង់ត្រូវតែងើបឡើងនៅក្នុងកំលាំងនៃព្រះ ហើយដឹកនាំ ។ តែទីបំផុតបែរជាមានអ្នកគង្វាលដាវីឌដ៏តូចម្នាក់ ជាអ្នកដែលគ្មានឋានៈបានងើបឡើងយ៉ាងខ្លាំងក្លានៅក្នុងកំលាំងនៃព្រះ ហើយដឹកនាំ អ៊ីស្រាអែល នៅក្នុងថ្ងៃដ៏ស្លាប់រស់នោះប្រឆាំងនឹងសត្រូវរបស់ខ្លួនទៅវិញ ។ វាជាកំហុសរបស់ស្តេចសូល ។ នៅពេលដែលទាហានវិលត្រឡប់ពីសង្គ្រាមមកវិញ ស្រីៗបានចេញមកជួបពួកគេ ហើយអបអរសាទរ ដាវីឌជាងអបអរស្តេច ដោយនិយាយថា "ស្តេចសូលបានសំលាប់តែមួយពាន់ តែដាវីឌបានសំលាប់មួយម៉ឺនវិញ" ។

នេះមិនមែនជាលើកដំបូងទេដែលស្តេចសូល មានឋានៈជាស្តេចផង និងជាអ្នកដឹកនាំផងបានទទួលបរាជ័យក្នុងការដឹកនាំនោះ ។ នៅក្នុងសាំយូអែល ១៤:១ បុត្រារបស់ស្តេចសូល យ៉ូណាថាន់ បានចាប់ផ្តើមទុកចិត្តព្រះ ដោយនាំពួកអ៊ីស្រាអែលប្រយុទ្ធតទល់ទៅនឹងសត្រូវរបស់ ខ្លួន ។ ខ. ២ បានបង្ហាញឲ្យយើងឃើញនូវអ្វីដែលស្តេចកំពុងធ្វើ គឺទ្រង់អង្គុយក្រោមដើមទទឹមជាមួយទាហានរបស់ទ្រង់ ៦០០នាក់ ។ បន្ទាប់មក នៅក្នុង ជំពូក១៥ ទ្រង់ទទួលសំណូមពរពីអ្នកដទៃ ដែលចូលទៅក្នុងការមិនស្តាប់បង្គាប់ទៅនឹងព្រះរាជបញ្ជារបស់ព្រះ ទ្រង់មិនបានឈរនៅក្នុងជំហរ ហើយដឹកនាំប្រឆាំងទៅតាមសេចក្តីប្រាថ្នារបស់ពួកគេ ។ វាគ្មានការសង្ស័យឡើយ គឺរាជវង្សរបស់សូលមិនទៅគង់វង្សយូរអង្វែងទៀតឡើយ ហើយព្រះបានរកឃើញម្នាក់ផ្សេងទៀតដែលដឹកនាំរាស្ត្ររបស់ទ្រង់តាមព្រះហឫទ័យរបស់ទ្រង់វិញ ។

ការនាំមុខមានន័យថា ពេលខ្លះយើងត្រូវតែមានជំហរឲ្យបានរឹង មាំ និងពេលខ្លះមានជំហរតែម្នាក់ឯង ។ ព្រោះពេលខ្លះប្រហែលជាអ្នក ដទៃ គេមានការភ័យខ្លាច ឬគេងលក់ ឬធ្វើជាមិនដឹង ហើយដើរចុះផ្លូវ មួយដែលខុស ។ ដូច្នេះហើយ នៅពេលដែលអ្នកដឹកនាំឈរយ៉ាងខ្ពស់ ហើយនិយាយយ៉ាងខ្លាំងក្លាទៅលើអ្វីដែលត្រូវតែធ្វើឲ្យបានសំរេច សូម្បី តែការធ្វើរបស់គាត់មិនឲ្យគាត់ល្បីល្បាញក៏ដោយ ។ គាត់ធ្វើយ៉ាងដូច្នេះ មិនមែនដើម្បីសាងឋានៈរបស់ខ្លួនឡើយ ប៉ុន្តែសំរាប់សេចក្តីពិតវិញ ។ លោកអេលីយ៉ាជាអ្នកដឹកនាំដ៏ខ្លាំងក្លាម្នាក់ ដែលគាត់ងើបឈរតែម្នាក់ឯង ប្រឆាំងនឹងយេសេបែលដែលមានហោរ៉ារបស់ព្រះបាល ៤០០នាក់ ។ គាត់ធ្វើយ៉ាងដូច្នេះមិនមែនសំរាប់ខ្លួនឯងទេ ប៉ុន្តែសំរាប់សេចក្តីពិត ។ លោក យេរេមា និងហោរ៉ាសញ្ញាចាស់ផ្សេងៗទៀត តែងតែឈរនៅក្នុង ជំហរដែលមិនល្បីល្បាញ ។ លោកប៉ុលប្រឆាំងទៅនឹងលោកពេត្រុស ទល់មុខតែម្តងនៅក្នុង កាឡាទី ជំពូក២ ។ គាត់ធ្វើយ៉ាងដូច្នេះមិនមែន ដើម្បីចង់ចំណោញអំណាចមកលើខ្លួនគាត់ ឬចំណោញកេរ្តិ៍ឈ្មោះមកពី ពេត្រុស នោះទេ ប៉ុន្តែពីព្រោះតែពេត្រុសបានធ្វើខុស ។ លោកពេត្រុស ត្រូវការការកែរតំរង់ មុនដែលគាត់នាំមួយផ្នែកធំនៃក្រុមជំនុំចូលទៅក្នុង ភាពខុសឆ្គង ។

ដូច្នេះទោះបីជាអ្នកដឹកនាំល្អ ទីមួយគឺដើរតាម និងមិនមែនបោក បញ្ឆោតអ្នកដទៃតាមរយៈការហ្វឹកហ្វឺន និងឱកាសផ្សេងៗដើម្បីធ្វើឲ្យគ្រប់ គ្នាមានការចាប់អារម្មណ៍មកលើខ្លួនឯងនោះឡើយ ។ នៅពេលនោះគាត់ មានការបំរើដោយអស់ពីចិត្ត ដោយឈរក្នុងជំហរដ៏រឹងមាំ ហើយបង្ហាញ ផ្លូវពួកគេនូវផ្លូវណាដែលត្រូវទៅ ។ អ្នកដឹកនាំល្អបំរើដោយការនាំមុខគេ។

ពីព្រោះតែអ្នកដឹកនាំត្រូវតែនាំមនុស្សរបស់គេ ជាដំបូងគាត់ត្រូវ ដឹងទិសដៅពិតប្រាកដដែលត្រូវទៅ ។ ហេតុដូច្នេះហើយបានជាតំរូវឲ្យ

គាត់ជាអ្នកដើរតាមល្អជាមុនសិន ។ អ្នកដឹកនាំត្រូវតែនាំ ប៉ុន្តែប្រសិនបើគាត់មិនដឹងកន្លែងណាដែលគាត់ត្រូវទៅពិតប្រាកដទេ នោះមានន័យថាគាត់មិនទាន់បានដើរកៀកជាមួយព្រះជាម្ចាស់នៅឡើយទេ ប្រហែលជាគាត់នាំចៀមរបស់គាត់ទៅរកភាពគ្រោះថ្នាក់ហើយ ។ នេះគឺជាអ្វីដែលព្រះយេស៊ូវចង់មានបន្ទូល នៅពេលដែលទ្រង់និយាយអំពីពួកផារិស៊ី "តាមតែគេចុះ គេជាមនុស្សខ្វាក់ដែលនាំមនុស្សខ្វាក់ បើមនុស្សខ្វាក់នាំមនុស្សខ្វាក់យ៉ាងដូច្នេះ នោះទាំងពីរនឹងធ្លាក់ទៅក្នុងរណ្តៅហើយ"[21] ។ ពួក ផារិស៊ីមិនបានដើរតាមព្រះអម្ចាស់ទេ ។ ដូច្នេះទោះបីជាពួកគេបានធ្វើការងារពួកគេក្នុងនាមជាអ្នកនាំមុខគេក៏ដោយ ពួកគេមិនដឹងថានឹងទៅកន្លែងណាទេ ហើយនាំចៀមរបស់គេឲ្យធ្លាក់រណ្តៅទៅវិញ ។ អ្នកដឹកនាំល្អស្គាល់ផ្លូវដែលគាត់ត្រូវទៅ ហើយបន្ទាប់មកខំពុះពារយ៉ាងខ្លាំងក្លាដោយសេចក្តីក្លាហាន ដោយនាំមនុស្សរបស់គេទៅរកផ្លូវនោះ ។

## អ្នកដឹកនាំល្អគឺជាអ្នកដែលហុចកំណាត់ឈើរត់ប្រណាំងបន្តទៅឲ្យអ្នកដទៃ

ល្បែងរត់ប្រណាំងគឺជាកីឡាដ៏ល្បីល្បាញមួយ ។ កីឡាករទ្រោបចុះពីក្រោយខ្សែបន្ទាត់ និងនៅពេលដែលកាំភ្លើងត្រូវបានបាញ់ឡើង គ្រប់គ្នាត្រូវចាប់ផ្តើមរត់ឆ្ពោះទៅរកទីដៅរៀងៗខ្លួន ។ ការប្រកួតភាគច្រើន គឺមានតែម្នាក់ៗ ។ អ្នកប្រកួតនីមួយៗ ដែលមានតែម្នាក់ៗ គឺខ្លួនគេនោះឯងជា "ក្រុម" របស់គេ ។ ទោះជាគេធ្វើយ៉ាងណា ចាញ់ ឬឈ្នះ គឺស្ថិតលើខ្លួនរបស់គេផ្ទាល់ ។ គាត់គ្មានដៃគូទេ ។ ប៉ុន្តែការប្រកួតខ្លះមានក្រុមដៃគូមួយក្រុម ។ ក្រុមដៃគូមួយក្រុមនោះប្រហែលជាមាន សមាជិក ៤នាក់ ។ នៅពេលដែលការប្រកួតចាប់ផ្តើម អ្នកដែលមានតួនាទីហុចកំណាត់ឈើតូចមួយឲ្យសមាជិកទីមួយកាន់ ។ នៅពេលដែលកាំភ្លើងបាញ់ឡើង

---

[21] *ម៉ាថាយ ១៥:១៤*

សមាជិកទីមួយនេះ រត់ជុំវិញទីលានដោយកាន់កំណាត់ឈើនេះជាប់ទៅ នឹងដៃ ។ បន្ទាប់មក នៅពេលដែលគេរត់មកដល់កន្លែងដើមវិញហើយ សមាជិកទីពីរដែលកំពុងរង់ចាំ រត់តាមដើម្បីទទួលកំណាត់ឈើពីសមាជិកទីមួយ ចំណែកឯសមាជិកទីមួយបញ្ចប់ជុំរបស់គេហើយ ។ សមាជិកទីពីរ នៅពេលដែលទទួលកំណាត់ឈើរួចហើយ ក៏រត់ជុំទីលានបន្តទៀត ។ នៅពេលដែលគាត់រត់ជុំទីលាន ហើយជិតដល់បន្ទាត់ចាប់ផ្ដើមវិញហើយ សមាជិកទីបីនៃក្រុមនោះកំពុងរង់ចាំ ។ ម្ដងទៀត កំណាត់ឈើមួយនោះត្រូវហុចឲ្យម្នាក់ទៀត ដោយសមាជិកទីពីរហុចឲ្យសមាជិកទីបីទទួល ។ ដំណើរការណ៍នេះបន្តរហូតដល់សមាជិកទាំងអស់នៅក្នុងក្រុមមានឱកាសរត់ជុំវិញទីលាន ដែលកាន់កំណាត់ឈើជាប់នឹងដៃ ។ អ្នកដែលឈ្នះនៅក្នុងការប្រកួតនេះ មិនមែនម្នាក់ណាមួយទេ ប៉ុន្តែជាក្រុមដែលរត់ជាមួយគ្នាបានយ៉ាងល្អ មិនរអាក់រអួល និងហុចកំណាត់ឈើបានយ៉ាងត្រឹមត្រូវ ។ ប្រសិនបើមានសមាជិកណាម្នាក់នៅក្នុងក្រុមមិនបានសហការល្អជាមួយអ្នកឯទៀត ដូចជាអ្នកដែលរត់ជាមួយដើម្បីទទួលកំណាត់ឈើ និងអ្នកដែលត្រូវហុចកំណាត់ឈើឲ្យអ្នកដែលទទួលដើម្បីកាន់ឲ្យបានជាប់ល្អនោះទេ នោះពួកគេមិនអាចឈ្នះបានឡើយ ។ ទោះបីជាម្នាក់ៗនៅក្នុងក្រុមមានការរត់លឿនជាងគេបំផុតយ៉ាងណាក៏ដោយ ប្រសិនបើគេមិនបានហុចឲ្យបានល្អ និងអ្នកទទួលមិនបានទទួលយកឲ្យបានត្រឹមត្រូវ នោះក្រុមរបស់គេនឹងចាញ់ជាមិនខាន ។ ការរត់ប្រណាំងជាក្រុម មិនមែនធ្វើឡើងដោយម្នាក់ៗឯងនោះទេ ប៉ុន្តែជាការធ្វើឡើងជាក្រុមវិញ ។

ភាពជាអ្នកដឹកនាំគ្រីស្ទបរិស័ទគឺយ៉ាងដូច្នេះឯង ។ យើងមិនមែនស្ថិត នៅក្នុងថ្នាក់ដឹកនាំដើម្បីធ្វើឲ្យគេមានចាប់អារម្មណ៍មកលើយើងថា យើងដឹកនាំ ឬផ្សាយដំណឹងល្អ ឬបង្រៀន ឬអធិប្បាយបានល្អនោះទេ ។

យើង គ្រាន់តែជាផ្នែកមួយនៃក្រុមដែលយើងត្រូវបានត្រាស់ហៅឲ្យទទួលចំណែកដើម្បីអាចធ្វើការយ៉ាងប្រសើរដែលអាចធ្វើបាន ហើយបន្ទាប់មកហុចកំណាត់ឈើឲ្យអ្នកដទៃទៀត ។

ព័ន្ធកិច្ចគ្រីស្តបរិស័ទបានចាប់ផ្តើមឡើងជាមួយព្រះយេស៊ូ ។ នៅពេលមួយចូលមកដល់ ទ្រង់ត្រូវបញ្ចប់ព័ន្ធកិច្ចរបស់ទ្រង់ដោយសុគតសំរាប់យើង ត្រូវបានរស់ឡើងវិញ ហើយវិលត្រឡប់ទៅឯនគរស្ថានសួគ៌ ទ្រង់បានហុចកំណាត់ឈើនៃព័ន្ធកិច្ចឲ្យសាវ័ករបស់ព្រះអង្គ ។ ទ្រង់បានមានព្រះបន្ទូលទៅពួកគេថា "តែឥឡូវនេះ ខ្ញុំទៅឯព្រះអង្គដែលចាត់ឲ្យខ្ញុំមក... ប៉ុន្តែអ្នករាល់គ្នាមានចិត្តពេញដោយសេចក្តីព្រួយ ។ ខ្ញុំប្រាប់តាមត្រង់ថា ដែលខ្ញុំទៅនោះមានប្រយោជន៍ដល់អ្នករាល់គ្នាវិញ ដ្បិតបើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ តែបើខ្ញុំទៅ នោះខ្ញុំនឹងចាត់ទ្រង់ឲ្យមក"[២២] ។ ក្រោយមកទៀតទ្រង់មានព្រះបន្ទូលថា "ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅដូចជាព្រះវបិតាបានចាត់ឲ្យខ្ញុំមកដែរ"[២៣] ។ ព្រះយេស៊ូបានចាកចេញ ព្រះអង្គបានប្រគល់ការងារដល់ពួកគេ ហើយទ្រង់នឹងបញ្ជូនព្រះ វិញ្ញាណដ៏វិសុទ្ធមកដើម្បីជួយពួកគេឲ្យសំរេចការទាំងអស់នោះបាន ។

ដូច្នេះ ពួកសាវ័កទទួលបន្តពីកន្លែងដែលព្រះយេស៊ូបានបញ្ឈប់។ ព្រះគម្ពីរសញ្ញាថ្មីបាននិយាយអំពីសាវ័ករបស់ព្រះយេស៊ូថា ជាអ្នកដាំជើងជញ្ជាំងនៃក្រុមជំនុំ[២៤] ។ ប៉ុន្តែពួកសាវ័កមិនបានធ្វើរហូតតទៅនោះទេ តាមរយៈពួកគេខ្លះបានធ្វើយ៉ាងល្អ និងព័ន្ធកិច្ចរបស់គេបានចាប់ផ្តើមក្រុមជំនុំ ។ ពេលមួយមកដល់ គឺពួកគេត្រូវប្រគល់ការងារនោះទៅអ្នកឯទៀត

[22] *យ៉ូហាន ១៦:៥-៧*

[23] *យ៉ូហាន ២០:២១*

[24] *១កូរិនថូស ៣:១០-១២: អេភេសូរ ២:២: វិវរណៈ ២១:១៤*

។ ចូរមើលពីគំរូសាវ័កប៉ុលទុកជាឧទាហរណ៍ គឺគាត់ត្រូវបានបញ្ជូនផ្ទាល់ដោយ ព្រះគ្រីស្ទ គាត់បានធ្វើការងាររបស់គាត់បានល្អ ហើយបន្ទាប់មកបានប្រគល់ការងាររបស់គាត់នោះទៅឲ្យធីម៉ូថេទទួលវិញ ដោយលោកប៉ូល ផ្តល់ការណែនាំដ៏សំខាន់ៗដល់សិស្សរបស់គាត់ដោយនិយាយថា "ឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន នោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹងបង្ហាត់បង្រៀនតទៅអ្នកឯទៀតដែរ"[25] ។ ធីម៉ូថេបានទទួលកំណាត់ឈើមកពីសាវ័ក ប៉ុល រត់ក្នុងទីលានរបស់គាត់ ហើយបន្ទាប់មកប្រគល់កំណាត់ឈើឲ្យអ្នក "ស្មោះត្រង់" ដែលអាចរត់ក្នុងទីប្រណាំងបាន ហើយបន្ទាប់មកទៀតអាច "បង្ហាត់បង្រៀនដល់អ្នកឯទៀត" ។ ព័ន្ធកិច្ចគ្រីស្ទបរិស័ទ មិនមែនជាការរត់ប្រណាំងម្នាក់ឯងនោះទេ ហើយក៏មិនមែនខំប្រឹងប្រែងដើម្បីឲ្យគេចាប់អារម្មណ៍ថាខ្លួនឯងជាតួឯក និងជាវិរបុរសនោះដែរ ។ វាជាការរត់ប្រណាំងជាក្រុម នៅពេលដែលយើងទទួលព្រះបន្ទូលហើយ នោះយើងជាអ្នកដំបូងដែលត្រូវចែកចាយព្រះបន្ទូលនេះដល់អ្នកឯទៀត បន្ទាប់ពីយើងរត់ក្នុងទីលានដ៏ខ្លីរបស់យើងរួចហើយ ស្វែងរកនរណាម្នាក់ដែលយើងអាចផ្ទេរការងាររបស់យើង ឲ្យទទួលខុសត្រូវជំនួសយើងបាន ។

ក្នុងនាមជាអ្នកដឹកនាំ យើងត្រូវតែព្យាយាមស្វែងរកមនុស្សល្អៗមួយចំនួនតូច ដែលយើងអាចបណ្តាក់ទុនកំលាំងរបស់យើងបន្ថែម ដើម្បីឲ្យថ្ងៃមួយ ពួកគេអាចទទួលដោយស្រួល និងមានដំណើរការល្អ ។ ដូចជាការរត់ប្រណាំងជាក្រុម ពួកគេមិនអាចឈ្នះបានទេប្រសិនបើក្រុមមួយធ្លាក់កំណាត់ឈើ ឬមិនបានហុចឲ្យគ្នាឲ្យបានល្អ ដូចគ្នាដែរព័ន្ធកិច្ចគ្រីស្ទបរិស័ទរបស់យើង នឹងជួបនូវការរងទុក្ខប្រសិនបើយើងមិនមាន

[25] ២ធីម៉ូថេ ២:២

មនុស្សដែលបានទទួលនូវការហ្វឹកហ្វឺន និងប្រុងប្រៀបដើម្បីទទួលកិច្ចការបន្ត នៅពេលដែលយើងចាកចេញទៅ ។

ដោយព្រោះព្រះយេស៊ូជ្រាបថាមិនយូរទេទ្រង់ត្រូវសុគតលើឈើឆ្កាង ហើយលាចាកផែនដីនេះទៅ បានជាទ្រង់ចំណាយពេលជាច្រើនឆ្នាំចុងក្រោយរបស់ព្រះអង្គ ក្នុងការហ្វឹកហ្វឺនសិស្សរបស់ព្រះអង្គ ។ បន្ទាប់ពីលោកពេត្រុសអាចសរុបបានថា ព្រះយេស៊ូគឺជាព្រះមែស្ស៊ី របស់អ៊ីស្រាអែលរួចមកព្រះយេស៊ូ "ចាប់ផ្តើមពន្យល់សិស្សរបស់ព្រះអង្គថាទ្រង់ត្រូវតែទៅក្រុងយេរូសាឡិម ហើយត្រូវរងទុក្ខ..."[២៦] ។ វាហាក់បីដូចជាទ្រង់ចំណាយពេលច្រើនជាមួយពួកគេ ហើយភាគតិចជាមួយបណ្តាជន ។ ជំនួសឲ្យធ្វើការប្រកាសដំណឹងល្អតែអង្គទ្រង់ផ្ទាល់គឺទ្រង់បញ្ជូនអ្នកទាំង១២ ហើយក្រោយមកទៀត ៧០នាក់ថែមទៀត ទៅប្រកាសដំណឹងល្អ និងបង្រៀន។ ជាជាងឲ្យទ្រង់ឈរតែម្នាក់ឯង ហើយបង្រៀនគឺទ្រង់ប្រទានឱកាសឲ្យអ្នកដទៃទៀតដើម្បីរៀនពីជំនាញ ទោះបីជាទ្រង់អាចធ្វើល្អជាងពួកគេក៏ដោយ ។ ទ្រង់បានរៀបចំពួកគេឲ្យទទួលកំណាត់ឈើដើម្បីរត់បន្តទៀត ។

ដូច្នេះប្រសិនបើយើងក្លាយជាអ្នកដឹកនាំល្អ យើងមិនមែនគ្រាន់តែធ្វើការងារផ្ទាល់ខ្លួនរបស់យើងបានល្អតែប៉ុណ្ណោះទេ យើងត្រូវតែបន្តក្នុងការហ្វឹកហ្វឺនអ្នកឯទៀតដើម្បីទទួលកន្លែងរបស់យើង ។ តើអ្នកកំពុងធ្វើការនេះហើយឬនៅ? តើអ្នកមានរណាម្នាក់ហើយឬនៅ ដែលជួបជាមួយ អ្នកដើម្បីរៀនព្រះគម្ពីរ និងអធិដ្ឋានជាមួយគ្នា? តើអ្នកបាននាំអ្នកដទៃទៅជាមួយអ្នក នៅពេលដែលអ្នកចេញទៅធ្វើការ ដើម្បីឲ្យគេអាចសង្កេត... និងអាចចែកចាយ... ហើយបន្ទាប់មកអាចជំនួសអ្នកបានហើយឬនៅ?

---

[26] *ម៉ាថាយ ១៦:២១*

សំណុំនិគ្ឃុំ ៤/១ (មករា ២០០៣): ១៣៧-១៥៧



# ព្រះជាម្ចាស់ផ្លាស់ក្តីទុក្ខសោកមក ជារបាំ (សេចក្តីអំណរឡើងវិញ)

*គីមខាន់ ណូរ៉េន*
(ដែលពីមុនគេស្គាល់ថាឈ្មោះ តៃ ខុនណាង)

នៅពេលខ្ញុំក្រឡេកមើលជីវិតខ្ញុំពីមុនមក ខ្ញុំអាចឃើញព្រះជាម្ចាស់ទ្រង់ល្អក្រៃលែង ទ្រង់បានធ្វើអន្តរាគមន៍រំដោះជីវិតខ្ញុំឲ្យរួចពីការអស់សង្ឃឹម និងរួចពីគ្រោះមហន្តរាយផ្សេងៗម្តងហើយម្តងទៀត ។ ដោយឆ្លុះបញ្ចាំងលើពាក្យសម្តីរបស់ស្តេចដាវីឌ នៅក្នុងគម្ពីរទំនុកដំកើង ៣០:១១ ខ្ញុំមើលឃើញជីវិតរបស់ខ្ញុំមកដល់ក៏រិតដូចជាស្តេចដាវីឌ បានរៀបរាប់ពិតប្រាកដមែន គឺច្បាស់ណាស់ព្រះជាម្ចាស់បានផ្លាស់ប្តូរទុក្ខសោករបស់ខ្ញុំទៅជារបាំ (ទៅជាអំណរឡើងវិញ) ។

កាលខ្ញុំនៅតូចមានម្តងនោះខ្ញុំបានធ្លាក់ទៅក្នុងស្ទឹង ហើយស្ទើរតែលង់ទឹកស្លាប់ ។ ប៉ុន្តែព្រះបានផ្តល់ប្រាជ្ញាដល់ខ្ញុំ ឲ្យខ្ញុំបានប្រើជើងខ្ញុំធាក់ដីបាតស្ទឹង ដើម្បីឲ្យខ្ញុំបានងើបផុតពីផ្ទៃទឹកសំរាប់ដកដង្ហើមពីមួយពេល ទៅមួយពេល បន្ទាប់មកព្រះជាម្ចាស់ប្រទានសត្វទាមួយហ្វូងតូចចុះមកហែលនៅពីមុខខ្ញុំបណ្តោយទឹកហូរ ដើម្បីទាញអារម្មណ៍មនុស្សដែលនៅលើស្ពានឲ្យយល់ថាខ្ញុំហែលតាមចាប់ទា ដោយសារព្រះគុណ

ព្រះជាម្ចាស់ មានសាច់ញាតិម្នាក់បានឃើញខ្ញុំមុជងើបៗនៅក្នុងទឹក ក៏យល់ថាខ្ញុំលង់ទឹក ហើយបានប្រញាប់ប្រញាល់មកសង្គ្រោះខ្ញុំ ។

ខ្ញុំមិនដែលបានស្គាល់ឪពុកខ្ញុំសោះ ពីព្រោះគាត់បានស្លាប់នៅដែលខ្ញុំអាយុបាន៦ខែ ប៉ុន្តែខ្ញុំមានភាពស្និទ្ធស្នាលជាមួយម្តាយខ្ញុំណាស់ បន្ទាប់មកពេលដែលខ្ញុំអាយុ បាន៨ឆ្នាំ ម្តាយខ្ញុំក៏ស្លាប់ទៀត ។ នៅពេលដែលគាត់ត្រដររខ្យល់ដង្ហើមចុងក្រោយរបស់គាត់នៅក្នុងអង្រឹង ខ្ញុំបានគេងជិតអង្រឹងរបស់គាត់ ហើយខ្ញុំក៏និមិត្តឃើញសត្វស្វាដ៏អាក្រក់ពីរធំៗសែងអង្រឹងម្តាយខ្ញុំចេញទៅ ។ ខ្ញុំឃើញខ្លួនខ្ញុំរត់តាមសត្វស្វាទាំងពីរនោះហើយស្រែកយំ សុំឲ្យសត្វនោះនាំយកម្តាយខ្ញុំមកវិញ ។ ស្រាប់តែខ្ញុំឃើញអណ្តូងជ្រៅៗជាច្រើនដូចជាអំបែងនំគ្រក់នៅឆ្វេងស្តាំ និងនៅខាងមុខខ្ញុំ ហើយនៅក្នុងអណ្តូងនិមួយៗមានពាសពេញទៅដោយសត្វស្វាដ៏អាក្រក់ជាច្រើនរាប់លានក្បាលគួរព្រឺក្បាលណាស់ សត្វស្វាបានសែងអង្រឹងម្តាយខ្ញុំឆ្ងាយទៅៗចូលក្នុងភាពងងឹត ខ្ញុំស្រែកយំដង្ហើយកាន់តែខ្លាំងឡើងៗរកម្តាយខ្ញុំឲ្យមកវិញ ស្រាប់តែរំពេចនោះខ្ញុំលឺសូរសំលេងម្តាយខ្ញុំស្រែកហាមខ្ញុំថា "ឈប់សិន! កុំមកតាមម្តាយអី កុំសាកល្បងតាមទៀតអី ប្រយ័ត្នធ្លាក់អណ្តូង ចូលទៅវិញទៅ" ។ ពេលខ្ញុំភ្ញាក់ឡើង សាច់ញាតិខ្ញុំបានប្រញាប់ប្រញាល់យកម្តាយខ្ញុំទៅមន្ទីរពេទ្យ ប៉ុន្តែហួសពេលហើយ ។ ជីដូនខ្ញុំបានប្រាប់ថា ម្តាយខ្ញុំបានស្លាប់ហើយ ។ ហើយពួកគាត់បានកប់ម្តាយខ្ញុំចូលក្នុងដី ។ នៅពេលនោះ ទំហំនៃទុក្ខសោករបស់ខ្ញុំវាធំហួស រហូតដល់ទៅយំក៏មិនចេញ ។

ប៉ុន្តែខ្ញុំជឿថា ព្រះជាម្ចាស់បានប្រើនិមិត្តអំពីឋាននរកនោះឲ្យខ្ញុំឃើញ ដើម្បីរៀបចំជីវិតរបស់ខ្ញុំឲ្យទទួលសេចក្តីសង្គ្រោះនៅពេលក្រោយ ។ ពេលដែលវ័យខ្ញុំកំពុងតែចំរើនឡើង ខ្ញុំបានចាប់ចិត្តជាខ្លាំងចំពោះកំណាព្យបុរាណ និងរឿងបុរាណដែលម្តាយ និងលោកយាយរបស់ខ្ញុំ

បានបង្រៀន ។ ជាពិសេស គឺលោកយាយរបស់ខ្ញុំចូលចិត្តទៅមើលល្ខោនបុរាណណាស់ គាត់តែងតែនាំខ្ញុំទៅជាមួយគាត់ជានិច្ច ។ ខ្ញុំក៏ ដូច្នោះដែរ ខ្ញុំ ចូលចិត្តយ៉ាងខ្លាំងចំពោះផ្ទាំងគំនូរដ៏មានតម្លៃដែលចែងរឿងជីវប្រវត្តិរបស់ព្រះពុទ្ធ ដែលគូរនៅលើជញ្ជាំងវិហារនៅវត្ត ។ ហើយនៅសាលារៀន ខ្ញុំបានរៀនចេះសិល្បៈបុរាណផ្សេងៗខ្លះៗ ដូចជារបាំបុរាណ និងចម្រៀងបុរាណ ។

បន្ទាប់ពីម្តាយរបស់ខ្ញុំបានស្លាប់ទៅ លោកយាយរបស់ខ្ញុំបានថែរក្សាខ្ញុំ ។ គាត់ជាលោកយាយដែលមានចិត្តល្អណាស់ ។ ខ្ញុំស្រឡាញ់គាត់ខ្លាំងណាស់ ។ ប៉ុន្តែពេលដែលខ្ញុំអាយុបាន១៣ឆ្នាំ លោកយាយរបស់ខ្ញុំក៏បានស្លាប់ទៀត ។ ម្តងហើយម្តងទៀត សេចក្តីស្លាប់បានបំបែកខ្ញុំពីមនុស្សដែលខ្ញុំស្រឡាញ់ ។

បន្ទាប់ពីនោះមក គ្មាននរណាកំឡាទឹកចិត្តខ្ញុំឲ្យចាប់អារម្មណ៍ពីសិល្បៈទៀតឡើយ ។ ខ្ញុំបានរស់នៅក្រោមអំណាចដ៏តឹងរឹងរបស់ម្តាយមីងបង្កើតរបស់ខ្ញុំ ។ គាត់ចិញ្ចឹមខ្ញុំហាក់ដូចជាទាសករ មិនមែនជាសាច់ញាតិជិតដិតឡើយ ។ ខ្ញុំបានធ្វើការផ្ទះសព្វគ្រប់បែបយ៉ាង និងមូរបារីលក់ទាំងយប់ទាំងថ្ងៃក្នុងមុខជំនួញរបស់គាត់ ដោយពុំសូវមានពេលនឹងធ្វើមេរៀនពីសាលា ហើយក៏គេងមិនគ្រប់គ្រាន់ដែរ ។

ពេលខ្ញុំបានធំដឹងក្តីបន្តិចមក ខ្ញុំបានសំរេចចាកចេញពីម្តាយមីងដែលនៅខេត្តសៀមរាប មករស់នៅជាមួយបងប្រុសបង្កស់របស់ខ្ញុំនៅភ្នំពេញ ដើម្បីនឹងប្រលងបញ្ចប់ការសិក្សា ប្រលងយកសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។ ប៉ុន្តែរយៈពេលនោះបងប្រុសខ្ញុំបានរៀបការប្រពន្ធហើយ គាត់គ្មានពេលនឹងយកចិត្តទុកដាក់ជាមួយខ្ញុំទេ ហើយប្រពន្ធគាត់ក៏ពូកែរករឿងខ្ញុំទៀត និងរឿងរ៉ាវក្នុងគ្រួសារជាកង្វល់យ៉ាងខ្លាំងដែលមិនអនុញ្ញាតឲ្យខ្ញុំរៀនតទៅមុខបានទៀត បន្ទាប់មកខ្ញុំបានសញ្ញាប័ត្រ

មធ្យមសិក្សាទុតិយភូមិ រួចហើយខ្ញុំបានសំរេចចិត្តថា ខ្ញុំអាចថែរក្សាខ្លួនខ្ញុំបានហើយ ខ្ញុំមិនត្រូវការអ្នកណាឲ្យចិញ្ចឹមខ្ញុំទៀតទេ ។ ខ្ញុំក៏បានស្វែងរកផ្លូវសំរាប់ជួយខ្លួនឯង ក៏បានប្រឡងជាប់ចូលមជ្ឈមណ្ឌលគរុកោសល្យកំពង់កន្ទួត ហ្វឹកហ្វឺនជាគ្រូបង្រៀននៅទីនោះពីរឆ្នាំ ។ បន្ទាប់ពីទទួលសញ្ញាប័ត្រគ្រូបង្រៀនរួចមកខ្ញុំបានជ្រើសរើសចូលទៅបង្រៀននៅខេត្តកំពតដែលនៅទីនោះខ្ញុំបានជួប ហើយរៀបការជាមួយប្តីខ្ញុំឈ្មោះ គឹម សាលីន ក្នុងឆ្នាំ ១៩៦៧ ។ ជីវិតអាពាហ៍ពិពាហ៍របស់យើងមានសុភមង្គលណាស់ពេលនោះហើយដែលយើងមានកូនល្អៗបីនាក់ កូនប្រុសបងឈ្មោះ សាលីណា កូនស្រីទីពីរ លក្សី និងកូនស្រីពៅឈ្មោះ សុវណ្ណា ។

ក្នុងឆ្នាំ ១៩៧០ សង្គ្រាមនៅអាស៊ីភាគអាគ្នេយ៍បានចាប់ផ្តើមរាលដាលមកលើប្រទេសអព្យាក្រឹត្យកម្ពុជា ដូច្នោះហើយបានជាពួកយើងផ្លាស់ទីលំនៅពីខេត្តកំពត មកនៅក្រុងភ្នំពេញ ។

នៅថ្ងៃមួយក្នុងខែធ្នូ ឆ្នាំ ១៩៧៤ មិត្តភក្តិខ្ញុំឈ្មោះ អ្នកគ្រូ វ៉ា បានអញ្ជើញខ្ញុំទៅព្រះវិហារយេស៊ូជាមួយគាត់ ។ ដំបូងខ្ញុំសួរគាត់ថា "ទៅធ្វើអី?" ។ ប៉ុន្តែគាត់បានប្រាប់ខ្ញុំអំពីច្បាប់របស់ព្រះយេស៊ូគ្រីស្ទ "កាលណាអ្នកធ្វើទាននោះកុំឲ្យដៃឆ្វេងយល់ការពីដៃស្តាំធ្វើឡើយ" ពាក្យទាំងនោះត្រូវចិត្តខ្ញុំណាស់ ព្រោះខ្ញុំមិនសូវចូលចិត្តចរិកលក្ខណៈរបស់មនុស្សខ្លះ ដែលបានដាក់លុយធ្វើបុណ្យនៅវត្តសំរាប់តែបង្ហាញអំនួតរបស់គេតែប៉ុណ្ណោះ ច្បាប់របស់ព្រះយេស៊ូហាក់ដូចជាល្អណាស់សំរាប់ខ្ញុំ ។ ហើយខ្ញុំក៏បានយល់ព្រមទៅព្រះវិហារជាមួយមិត្តភក្តិខ្ញុំនៅពេលនោះ ។

